# គំរូអភិវឌ្ឍន៍សហគមន៍ចំរុះ អង្គការប៉ាដិក (គអសចប)

## ការអធិប្បាយយុទ្ធសាស្ត្រ និងបង្ហាញត្រួសៗអំពីគំរូរបស់យើង




**គ្រោងការងារ:** គំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិក

### មាតិការឿង


១-ហេតុអ្វីបានជាបង្កើតឯកសារនេះឡើង ០២
- *អំពីប៉ាដិក*
- *កសាងការទុកចិត្តគ្នាដើម្បីផ្លាស់ប្តូរ*

២-អង្គការប្រជាជន ០៥
- *ទទួលខុសត្រូវរួមគ្នា*

៣-មហាសន្និបាតប្រជាពលរដ្ឋ ០៧
- *ស្តាប់សំដីអ្នកក្រីក្រនិយាយ*

៤-អ្នកសំរបសំរួល ១០
- *គអភ និងគអឃ ធ្វើការរួមគ្នាដើម្បីផ្លាស់ប្តូរ*

៥-អ្នកឯកទេស ១៣
- *ជំនាញសំរាប់ការអភិវឌ្ឍន៍*

៦-ការងារនៅសហគមន៍ ១៥
- *កសិកម្មសមស្របជា រឺសគល់នៃសន្តិសុខស្បៀង*

៧-ការដាក់គំរូបញ្ចូលគ្នា ១៨



padek

បានទទួល មេដាយមាសស្ថាបនាជាតិឆ្នាំ២០០២ និង មេដាយមាសសហមេត្រី ឆ្នាំ២០០៣ ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



ការិយាល័យ: ផ្ទះលេខ ៧២ ផ្លូវលេខ ៣៦០ ភ្នំពេញ
ប្រអប់សំបុត្រ: PO.Box 554 ភ្នំពេញ
ទូរស័ព្ទលេខ: ៨៥៥-២៣-៣៦២-៧៧៩
ហ្វាក់: ៨៥៥-២៣-២១៦-២២៤
អ៊ីម៉េល: padek@everyday.com.kh
វិបសាយ: www.padek.org



បោះពុម្ពផ្សាយដោយ: ផ្សព្វផ្សាយពត៌មាន ដើម្បីផ្តល់អំណាច អង្គការប៉ាដិក Padek ភ្នំពេញ កម្ពុជា

*ឧបត្ថម្ភ ការបោះពុម្ពផ្សាយដោយ NOVIB (ណូវីប) និង EC គណៈកម្មការសហគមន៍អ៊ឺរ៉ុប*

ខែ កុម្ភៈ ឆ្នាំ ២០០៣


**អង្គការប៉ាដិក (Padek) សហប្រតិបត្តិការ ដើម្បីអភិវឌ្ឍន៍នៅកម្ពុជា**

# ១_ហេតុអ្វីបានជាបង្កើតឯកសារនេះឡើង?

## អំពីប៉ាដិក

អង្គការប៉ាដិក បានបង្កើតឡើងជាផ្លូវការនៅឆ្នាំ ១៩៨៦ ប៉ុន្តែអង្គការនេះមានវត្តមានតាំងពីឆ្នាំ ១៩៨១ មកម្ល៉េះ តែនៅពេលនោះមានរូបភាពជាសមាគមអង្គការ ដែលមានម្ចាស់អំណោយចំនួន ៥ រួមគ្នាមាន អុកស្វាមបែលហ្សិក អុកស្វាមអាមេរិក អុស្វាមហុងកុង ហ្វូស និងអុកស្វាមហូឡង់ (ណូវីប) ។

គំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិកជាការប្រមូលផ្តុំនូវបទពិសោធន៍របស់អង្គការប៉ាដិក ក្នុងវិស័យអភិវឌ្ឍន៍សហគមន៍ ក្នុងប្រទេសកម្ពុជា។ វាជាការវិវត្តន៍ដែលឆ្លើយតប ទៅតាមសេចក្តីត្រូវការរបស់អង្គការប៉ាដិក ក្នុងការបង្កើតឱ្យមានគ្រោងការមួយច្បាស់លាស់ ស្តីអំពីការងារអភិវឌ្ឍន៍ សហគមន៍ នៅតាមអង្គភាពគាំទ្រតំបន់ទាំង ៥របស់ខ្លួន ។

គំរូអភិវឌ្ឍន៍សហគមន៍ចំរុះ អង្គការប៉ាដិកនេះចាប់ផ្តើមនៅឆ្នាំ ១៩៩៩ ។ ក្រុមចាត់ចែងការងារព្រមទាំងបុគ្គលិក របស់អង្គការប៉ាដិក និងសហគមន៍ជាដៃគូ បានប្តេជ្ញាអនុវត្តន៍គំរូនេះថាជាមគ្គុទ្ទេសន៍មួយក្នុងការធ្វើផែនការ អន្តរាគមន៍ ដែលនាំមកនូវ ការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធក្នុងគំរោង។ គំរូនេះក៏ជាគ្រោងការមួយ ដែលជំរុញឱ្យមានសង្គមស៊ីវិល ច្រើនឡើងនៅតាមមូលដ្ឋាន ហើយជាវិធីមួយ ដែលផ្តល់លទ្ធផលប្រកបដោយយុត្តិធម៌ មិនមែនដោយការប្រទូស្តរាយគ្នា បែបហឹង្សា តែអនុវត្ត តាមរយៈការចែកចាយធនធានមួយ ប្រកបដោយមនសិកា លំអៀងទៅរកអ្នកក្រីក្រ ហើយដែលប្រជាជនមានលទ្ធភាពគ្រប់គ្រងនិងចាត់ចែងធនធានបានដោយខ្លួនឯង។

### ហេតុអ្វីបានជាបង្កើតឯកសារនេះឡើង ?

ឯកសារនេះគ្រាន់តែជាការណែនាំ ដល់អ្នកអានអំពីគំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិក តែប៉ុណ្ណោះ។ យើងមិនបានគិតថា គំរូអភិវឌ្ឍន៍សហគមន៍ ចំរុះនេះ ជាមធ្យោបាយដ៏ប្រសើរលើសគេ ដែលផ្តល់ផលប្រយោជន៍ ក្នុងការអភិវឌ្ឍន៍សហគមន៍នៅក្នុងប្រទេសកម្ពុជានោះទេ។

ទោះជាយ៉ាងនេះក៏ដោយ យើងសង្ឃឹមថាគំរូនេះនិងដើរតួជាឯកសារយោងមួយ សំរាប់ពិភាក្សា បន្ថែមទៀតនាពេលខាងមុខ នៅក្នុងវេទិកាស្តីពីការអភិវឌ្ឍន៍នាប្រទេសកម្ពុជាយើង។ ផ្អែកលើគំនិតនេះ គំរូអភិវឌ្ឍន៍ សហគមន៍ចំរុះអង្គការប៉ាដិក ជាយន្តការមួយជំរុញឱ្យមានគំនិតថ្មីៗថែមទៀតហើយមិនមែនជាអ្វី ដែលត្រូវតែធ្វើតាមឥតល្មៀងនោះទេ។

### *តើយើងអាចធ្វើការនៅកន្លែងណា ?*

អង្គការប៉ាដិកធ្វើការនៅក្នុង តំបន់គំរោងប្រាំៈ ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ សៀមរាប និងទីក្រុង ភ្នំពេញ។ ប៉ាដិកធ្វើការយ៉ាងយកចិត្តទុកដាក់ដោយកំណត់ការចាប់ផ្តើម ការងាររបស់ខ្លួនជាមួយ និងឃុំដែលក្រីក្របំផុត នៅក្នុងតំបន់គាំទ្រ ដូចខាងលើ។ នៅឆ្នាំ២០០២ យើងធ្វើការជាមួយ និងប្រជាជនចំនួនជាង ៣២០០០គ្រួសារនៅក្នុងឃុំ/សង្កាត់ តាមជនបទ និងទីក្រុងចំនួន២២ ។

(តនៅទំព័រទី ៣)



កសិករធ្វើការប្រវាស់ដៃគ្នា ក្នុងការផលិតដំណាំកសិកម្ម (កំពង់ស្ពឺ)

### គំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិក (គអសចប)
### កសាងការទុកចិត្តគ្នា ដើម្បីផ្លាស់ប្តូរ

ក្រោយពេលបញ្ចប់ទំនាស់នៅកម្ពុជា មានបញ្ហានានាជាច្រើន ហើយបញ្ហាទាំងនេះគឺ ជាការប្រឈមមុខយ៉ាងធំធេង សំរាប់អ្នកអភិវឌ្ឍន៍ទាំងឡាយ។ ចាប់ពីពេលដែលបានបង្កើតឡើងនៅឆ្នាំ១៩៨៦មក អង្គការប៉ាដិកបានកំណត់ បេសកកម្មរបស់ខ្លួន ដើម្បីស្វែងរក និងជំរុញ អោយកើតមាន ឡើងនូវគំរូអភិវឌ្ឍន៍ដែលមាននិរន្តរភាព មួយសំរាប់ប្រទេសកម្ពុជាសំរាប់ថ្នាក់មូលដ្ឋានក៏ដូចជានៅថ្នាក់ជាតិ។ ក្រោយពេលចាប់ផ្តើម បំពេញការងាររបស់ខ្លួនប៉ាដិក បានរកឃើញកត្តាខ្វះចន្លោះមួយ ដែលរារាំង ដល់ការអភិវឌ្ឍន៍ ប្រកបដោយសមធម៌នោះគឺការមិនទុកចិត្តគ្នា។

ការមិនទុកចិត្តគ្នានេះ

នេះជាកេរ្តិ៍ដំណែលបន្សល់ពីសង្គ្រាម និងទំនាស់ ដែលកម្ពុជាបានទទួលរងយ៉ាងធ្ងន់ធ្ងរអស់រយៈបីទស្សវត្សនោះ។

នៅក្នុងប្រទេសកម្ពុជា មានការមិនទុកចិត្តគ្នានៅក្នុងជួររដ្ឋាភិបាលតាមរយៈ រចនា

(តនៅទំព័រទី ៣)

> *"ការអភិវឌ្ឍន៍មនុស្ស ពិតប្រាកដមិនមែនគ្រាន់តែការធ្វើឱ្យសេដ្ឋកិច្ច លូតលាស់នោះទេ។ លទ្ធផលជាខ្លឹមសារ គឺការផ្តល់អំណាច និងការរីករាយចេញពីដួងចិត្តពិតៗ របស់មនុស្សម្នាក់"*
>
> -អ៊ុង សាន ស៊ូជី-

## ហេតុអ្វីបានជាបង្កើតឯកសារ....

អង្គភាពគាំទ្រតំបន់ ជាអ្នកទទួលការខុសត្រូវក្នុងការកសាង និងពង្រឹងសមត្ថភាពរបស់គូអង្គអភិវឌ្ឍន៍ ទាំងឡាយដើម្បីឱ្យចេះលើកផែនការធ្វើការត្រួតពិនិត្យ និងវាយតំលៃការងារអភិវឌ្ឍន៍សហគមន៍របស់ពួកគេ។

ភ្នាក់ងារសំរបសំរួលអភិវឌ្ឍន៍សហគមន៍ របស់អង្គការប៉ាដិកចំរុះដោយអ្នកជំនាញ តិកនិច និងជាអ្នកជំនាញទូទៅ ជាអ្នកបំផុសយ៉ាងសំខាន់ អោយមានការចូលរួមតាម គំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិក។

*ការរស់នៅតាមជនបទ និងការរស់នៅក្នុងក្រុង*

អ្នកជនបទ និងអ្នកក្រុង ប្រឈមមុខនឹងបញ្ហាផ្សេងៗគ្នាដែលឆ្លុះបង្ហាញ តាមរយៈសកម្មភាពទាំងឡាយរបស់ប៉ាដិកសំរាប់អភិវឌ្ឍន៍ជនបទ និងទីក្រុង។

សំរាប់កសិករក្រីក្រនៅជនបទ កសិកម្មសមស្របគឺជាមុខសញ្ញាសំខាន់ ដើម្បីបង្កើនជំនាញ និងចំណេះដឹងអំពីបច្ចេកទេសផលិតកម្ម ដោយប្រើប្រាស់ធនធានពីខាងក្រៅទាបបំផុត ។ជាទូទៅយើងឃើញថា ចំនួនអ្នកចេះអក្សរមានអត្រាខ្ពស់នៅទីក្រុងដូច្នោះយើងត្រូវយកចិត្តទុកដាក់ ជំរុញសកម្មភាពអក្ខរកម្ម សំរាប់មនុស្សពេញវ័យ និងកុមារនៅតំបន់ប៉ាដិកគាំទ្រតាមជនបទ។

ឥណទានដែលមានការប្រាក់ទាប គឺជាសេចក្តីត្រូវការ ដ៏សំខាន់សំរាប់អ្នកជនបទ ក៏ដូចជាអ្នកក្រុង។ ចំនួនប្រាក់សន្សំ និងប្រាក់កំចីក្នុងក្រុមជួយខ្លួនឯងជាទូទៅ នៅទីក្រុងមានកំរិតខ្ពស់ជាងនៅជនបទ។ ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថាការចំណាយសំរាប់ជីវភាពរស់នៅ របស់គ្រួសារនៅទីក្រុងភ្នំពេញមានតំលៃខ្ពស់ជាងនៅតាមជនបទ។

ចំពោះប្រជាជនរស់នៅតាមជនបទ ដាច់ស្រយាល គេប្រឈមមុខនិងបញ្ហាជាច្រើន។ មានគ្រួសារតិចជាងមួយភាគបីនៅជនបទ បានទទួលទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់។ សូម្បីតែពួកគាត់មានជំងឺបន្តិចបន្តួច ក៏ក្លាយជាការគំរាមកំហែងដល់អាយុជីវិតរបស់គាត់បានដែរ នៅក្នុងតំបន់ទាំងនោះ ដោយសារតែមិនមានសេវាថែរក្សាសុខភាពប្រកបដោយគុណភាព និងតំលៃថោកសំរាប់ពួកគាត់។

តំលៃកសិផលធ្លាក់ចុះ គឺជាកត្តាមួយប្រឆាំងនិងការខំប្រឹងប្រែង បង្កើនផលិតផលរបស់កសិករ។ ក្រុមហ៊ុនដាំដំណាំ កសិឧស្សាហកម្មដែលកាន់កាប់ដីមានទំហំធំ ក៏ជាកត្តាមួយធ្វើអោយប្រជាជន បាត់បង់ដីធ្លី។ បច្ចុប្បន្ននេះគ្រួសារកសិករប្រមាណ២០ភាគរយ ពុំមានដី។ ស្ថានភាពនេះ នឹងកាន់តែធ្ងន់ធ្ងរទៅៗ ប្រសិនបើទំរង់នៃការអភិវឌ្ឍន៍ នៅប្រទេសកម្ពុជាមិនមានការផ្លាស់ប្តូរទេនោះ។ ការរីកចំរើននៃសេដ្ឋកិច្ច ដែលកើតមានឡើង នៅរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះមិនបានជួយ លើកជីវភាពអ្នករស់នៅតាមជនបទទេ (CDRI ២០០២)។

អ្នកក្រីក្រនៅទីក្រុង ភាគច្រើនមកពីតំបន់ជនបទ។ ថ្វីត្បិតតែភាពក្រីក្រនៅជនបទ មានកំរិតខ្ពស់ (៤៣ភាគរយនៃគ្រួសារកសិករប្រៀបធៀប១១ភាគរយនៃអ្នករស់នៅទីក្រុង) ស្ថានភាពរស់នៅរបស់គ្រួសារក្រីក្រ នៅទីក្រុង មានភាពធ្ងន់ធ្ងរខ្លាំងណាស់។

ទីក្រុងភ្នំពេញ ពុំបានរៀបចំគ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការ នៃអ្នកដែលហូរចូលមករស់នៅថ្មីៗនោះទេដូចជា សុខភាព ការអប់រំ ផ្ទះសំបែង និងសេវាការងាររបស់ពួកគាត់។ អ្នកចំណាកស្រុកទាំងនោះ ត្រូវបង្ខំចិត្តមកផ្តុំគ្នារស់នៅតាមតំបន់អ្នកក្រីក្រ ដែលងាយបង្កភាពសៅហ្មង ព្រមទាំងអាចជាកម្លាំងគំរាមដល់ស្ថេរភាពជាតិ ដែលទើបតែបានទទួលនៅពេលថ្មីៗនេះ។

## គអសចបៈ កសាងការទុកចិត្តគ្នា

សម្ពន្ធ័ ខ្សែទទឹងនិងបណ្តោយ ការមិនទុកចិត្តគ្នារវាងរដ្ឋាភិបាលនិងប្រជាជន និងរវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល។

ដើម្បីកសាងការទុកចិត្តគ្នាឡើងវិញ គំរូវឱ្យមានការពិគ្រោះយោបល់ រវាងគូអង្គអភិវឌ្ឍន៍ទាំងឡាយ អ្នកវិទ្យាសាស្ត្រសង្គមបានសង្កេតឃើញថា មិនមានភាពងាយស្រួលទេក្នុងការចាប់ផ្តើមឡើងវិញ ការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងប្រជាជនក្នុងប្រទេសមួយ ដែលបានឆ្លងកាត់សង្គ្រាមអូសបន្លាយដូចនេះ ។ហើយនៅកម្ពុជាក៏ពិបាកដូច្នោះដែរ។

នៅពេលណា ដែលអ្នកពាក់ពន្ធ័ទាំងឡាយ គឺប្រជាពលរដ្ឋ រដ្ឋាភិបាលនិងម្ចាស់អំណោយ មិនមានសុឆន្ទៈ ឬមិនអាចចូលរួមពិគ្រោះយោបល់ គេមិនអាចរកឃើញការយល់ដឹងមួយរួមគ្នាទេ។ នៅពេលណាដែលអ្នកពាក់ពន្ធ័ មិនទុកចិត្តគ្នា ពេលនោះគ្មានការចូលរួមទទួលខុសត្រូវទេ។ នៅពេលនោះអ្វីដែលជាលទ្ធផល គឺបន្តភាពក្រីក្រ មិនមែនបន្តការអភិវឌ្ឍន៍ទេ។ ដោយហេតុនេះ យើងត្រូវស្វែងរកការទុក ចិត្តគ្នាឡើងវិញឱ្យបានឆាប់រហ័ស។

*តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល*

អាស្រ័យហេតុនេះ វាមានសារៈសំខាន់ណាស់សំរាប់ អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ក្នុងការធានាថារាល់អន្តរាគមន៍អភិវឌ្ឍន៍ ត្រូវរួមវិភាគទានដល់ការកសាងការទុកចិត្តគ្នា តាមរយៈការពិគ្រោះយោបល់ជាពិសេសរវាងរដ្ឋាភិបាល និងប្រជាជន។ ដើម្បីសំរបសំរួលឱ្យមានការពិគ្រោះយោបល់ អង្គការមិនមែនរដ្ឋាភិបាលនានា អាចអនុវត្តតាមវិធីពីរគឺ : ផ្តល់អំណាច ឱ្យប្រជាជនចេះនិយាយដោយខ្លួនឯង និងដើរតួជាអន្តរការីដោយនាំនូវកង្វល់ និងអត្ថប្រយោជន៍ទាំងឡាយរបស់ប្រជាជន ដាក់ជូនរដ្ឋាភិបាល និងអ្នកផ្តល់អំណោយគ្រប់ជាន់ថ្នាក់។

*ការពង្រឹងសំណាញ់សុវត្ថិភាព*

ដើម្បីធានាឱ្យ ការពិគ្រោះយោបល់នោះមានជោគជ័យ សំខាន់ប្រជាជនត្រូវបានទទួលពត៌មាន និងចំណេះដឹងពោលគឺ ការផ្តល់អំណាចឱ្យពួកគាត់។ ការផ្តល់អំណាចដល់ប្រជាជន ជាការងារដែលមានលក្ខណៈស្មុគស្មាញណាស់។ វាតំរូវឱ្យយើងស្វែងយល់ឱ្យបានច្បាស់លាស់ អំពីផ្ទៃសង្គមដែលមាននៅពេលនោះ : រចនាសម្ព័ន្ធសង្គមខ្លះផ្តល់នូវសេរីភាព និងរចនាសម្ព័ន្ធសង្គមខ្លះទៀតគៀបសង្កត់ប្រជាជន ព្រមទាំងបន្តឱ្យមានភាពក្រីក្រ។ ក្រុមប្រវាស់ដៃ គឺជារចនាសម្ព័ន្ធសង្គមមួយ ដែលនាំមកនូវសេរីភាព និងតំរូវឱ្យមានការថែបំប៉នបន្ថែមទៀត។ ពួកមេបុលទាំងឡាយគឺជារចនាសម្ព័ន្ធសង្គមដែលគៀបសង្កត់។ (តទៅទំព័រទី៤)

ជំនឿថាកុមារីមិនចាំបាច់ ចេះអាន ឬចេះសរសេរ ជារចនាសម្ពន្ធ័សង្គមក្បេរសង្កត់ ។

នៅក្នុងសង្គមក្រីក្រដែល រដ្ឋាភិបាលមិនអាចការពារសន្តិសុខ និងសុវត្ថិភាពដល់ប្រជាជន ប្រពន្ធ័មួយដែលមានទំនាក់ទំនងបែប "ចៅហ្វាយនាយ និងកូនចៅ" តែងតែកើតរាលដាលឡើង ។ ប្រពន្ធ័ក្រៅផ្លូវការនេះ ក្លាយជាមធ្យោបាយទំនាក់ទំនងផ្អែកសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ ។ តែក្នុងស្ថានភាព ដែលមានលក្ខណៈខុសគ្នាយ៉ាងធំធេងស្តីពីអំណាច និងការត្រួតត្រាធនធាននោះ អ្នកក្រីក្រត្រូវ បានក្លាយជាអ្នកដែលងាយទទួលការរំលោភ បំពាន ពីអ្នកមានអំណាច ។

គំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិក ធ្វើឡើងដើម្បីក្នុងគោលបំណងបំបាត់ ទំនាក់ទំនងបែប "ចៅហ្វាយនាយ និងកូនចៅ" នេះ ។យើងធ្វើតាមរយៈផ្តល់រចនាសម្ពន្ធ័ជាជំរើស ផ្សេងៗ នៅកំរិតសហគមន៍ និងដើម្បីពង្រឹងសំណាញ់សុវត្ថិភាពសង្គមក្នុងគោលបំណង កាត់បន្ថយការរងគ្រោះ ដោយអំពើរំលោភបំពានពីសមាសភាពសង្គមដែលមាននិន្នាការកេរ្យបសង្កត់គេ ។

ការរៀបចំសហគមន៍ដើម្បីផ្តល់អំណាច

អង្គការបាដក ប្រេគូអភវឌ្ឍនសហគមន ចំរុះ ដើម្បីបំពេញតួនាទីចំបង របស់អង្គការមិនមែនរដ្ឋាភិបាលគឺការផ្តល់អំណាច ។គំរូនេះបង្កើតឡើងលើទស្សនៈ ដែលថាអភិវឌ្ឍន៍សហគមន៍អាចទទួលជោគជ័យបានល្អិកណាមាន ការរៀបចំសហគមន៍ ដោយប្រុងប្រយត្ន័ជាមុន។ នៅពេលដែលកំលាំងទីផ្សារកំពុងរុញច្រានប្រជាជន អោយបែកខ្ញែកគ្នា គិតតែពី បញ្ហាបុគ្គល វាជាការសំខាន់ណាស់ដែលយើងត្រូវធ្វើ វិនិយោគ ឱ្យពួកគាត់អាចជួបជុំគ្នាដើម្បីគិតគូរ និងទាញយកនូវអត្ថប្រយោជន៍ពីលទ្ធផលនៃ ការរីកលូតលាស់ដោយសេដ្ឋកិច្ចសេរី ។

តួអង្គទាំងឡាយ នៅក្នុងគំរូអភិវឌ្ឍន៍សហគមន៍អង្គការប៉ាដិកជាអាទិ៍មានៈ ក្រុមជួយខ្លួនឯង គណៈកម្មការអភិវឌ្ឍន៍ភូមិ ឃុំ និងគណៈកម្មការឯកទេស គឺជាការខំប្រឹងប្រែងរបស់ប៉ាដិកក្នុងការរៀបចំសហគមន៍ដើម្បីផ្តល់អំណាច។ តួអង្គទាំងនេះ មានលក្ខណៈពឹងផ្អែកគ្នាទៅវិញទៅមក ហើយមានការទទួលខុសត្រូវ ចំពោះគ្នាទៅវិញទៅមកតាមវិធីមួយ ដែលនាំមកនូវភាពស្អិតរមួតសង្គម ដែលជាកត្តាចាំបាច់សំរាប់សហគមន៍ទាំងនោះ អភិវឌ្ឍន៍ប្រកបដោយសមធម៌ និងឆ្ពោះទៅរកការពឹងផ្អែក លើខ្លួនឯងបានយ៉ាងពេញលេញ ។

តួនាទីរបស់អង្គការប៉ាដិក ជាអន្តរការីសំរាប់ពាំនាំសំលេងរបស់អ្នកក្រីក្រ ផ្សារភ្ជាប់និងបកស្រាយ នូវបញ្ហាទាំងឡាយរបស់ប្រជាជនមូលដ្ឋានដើម្បីធ្វើឱ្យមាន ឥទ្ធិពលដល់ការកែទំរង់នៅថ្នាក់ជាតិ ។

អង្គការប៉ាដិកអនុវត្តតាមវិធីនេះ រហូតដល់ពេលណាប្រជាជនក្រីក្រ អាចនិយាយបញ្ចេញសំលេងដោយខ្លួនគេផ្ទាល់ បានតាមរយៈសង្គមស៊ីវិល ចេះធ្វើការតស៊ូមតិ ដើម្បីអោយរដ្ឋាភិបាល បំពេញបានពេញលេញ នូវតួនាទីរបស់ខ្លួន និងទទួលខុសត្រូវ ក្នុងការផ្តល់សន្តិសុខ និងសុវត្ថិភាពសង្គម ដល់ប្រជាជនគ្រប់រូបប្រកបដោយនិរន្តរភាព។

គ្រឹះនៃភាពរស់រវើករបស់ សង្គមស៊ីវិលមូលដ្ឋាន ដែលគំរូនេះជំរុញឱ្យមាន និងនាំមកនូវសន្ទុះយ៉ាងខ្លាំងមួយ ក្នុងការផ្លាស់ប្តូរដែលផ្អែកលើសភាពការណ៍ពិតប្រាកដនៅមូលដ្ឋាន។ គំរូនេះឈរលើការយល់ដឹងមួយដែលថាគ្រឿងផ្សំដ៏សំខាន់ សំរាប់កសាងសង្គមប្រជាធិបតេយ្យសេរីនោះគឺវប្បធម៌មួយដែលមានសង្គមស៊ីវិលច្រើនរីកដុះដាលដូចជាៈ សមាគម ក្លឹប គណៈកម្មការ និងអង្គការនានា ដែលបង្កើតឡើងជុំវិញបញ្ហាផ្សេងៗទាក់ទងនិង សេដ្ឋកិច្ចសង្គម វប្បធម៌ និងនយោបាយ ដែលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន។

✿



កុមារក្រីក្រ ក្លាតពីសំណាញ់ សន្តិភាពសង្គម គេរស់ដោយសារ គំនរសំរាម

## ផ្សព្វផ្សាយពត៌មានដើម្បីផ្តល់អំណាច

*នៅដើមឆ្នាំ២០០២ អង្គការប៉ាដិកបានចាប់ផ្តើមគំរោងបីឆ្នាំដែលឱ្យឈ្មោះថា "ផ្សព្វផ្សាយ ពត៌មាន ដើម្បីផ្តល់អំណាច "។ គំរោងនេះមានគោលបំណង ឆ្លើយតបទៅនឹងបញ្ហាទាក់ទងគ្នាពីរ ដែលកើតឡើងដោយសារសង្គ្រាម និងទំនាស់អស់បីទសវត្សរ៍កន្លងមក និងជាឧបសគ្គក្នុងការអភិវឌ្ឍន៍ ប្រទេសកម្ពុជាគឺៈ ភាពក្រីក្រ និងការមិនទុកចិត្តគ្នា ។ គំរោងនេះបន្តការងាររបស់ប៉ាដិកក្នុងការកសាងការទុកចិត្តគ្នានិងការកាត់បន្ថយភាពក្រីក្ររបស់ប៉ាដិកដោយអនុវត្តតាមវិធី២បែបៈ*

*-លើកទឹកចិត្តឱ្យមានការចែករំលែកពត៌មាន និងការផ្លាស់ប្តូរចំណេះដឹងរវាងអ្នកពាក់ព័ន្ធទាំងឡាយដើម្បីជួយគេក្នុងការកំណត់មូលហេតុពិតប្រាកដនៃភាពក្រីក្រនិងយុទ្ធសាស្ត្រដើម្បីប្រយុទ្ធនឹងភាពក្រីក្រទាំងនោះ ។*

*-លើកទឹកចិត្ត ឱ្យមានការចូលរួមយ៉ាងសកម្មគ្រប់អ្នកពាក់ព័ន្ធ ជាពិសេសរដ្ឋាភិបាលនិងប្រជាជន ដើម្បីចងក្រង និងលើកការកែទំរង់ដែលសំដៅកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រតាមវិធីមួយប្រកបដោយសមធម៌ ។*

*ឯកសារនេះជាផលិតផលនៃគំរោងផ្សព្វផ្សាយពត៌មានដើម្បីផ្តល់អំណាចរបស់អង្គ ការប៉ាដិក*

### ការពិចារណាអំពី សំណាញ់

ទីណាដែលគ្មានសេវាសង្គម ក្រឡាសំណាញ់រីកធំ ហើយប្រជាជនក្រីក្រ (តូចតាច) ត្រូវរបូត ធ្លាក់ចុះតាមចន្លោះនៃក្រឡានោះ ។ ដើម្បីធ្វើឱ្យក្រឡាសំណាញ់នោះញឹកគេ ត្រូវបង្កើតរចនាសម្ព័ន្ធថែមទៀតដើម្បីបំពេញចន្លោះនៅក្នុងសំណាញ់នោះហើយ ផ្តល់ឱ្យអ្នកក្រីក្រនូវជំរើសផ្សេងៗទៀតក្នុងការស្វែងរកជំនួយដល់ពួកគេ ។

# ២.អង្គការ ប្រជាជន




អង្គការប្រជាជន គឺជាក្រុមប្រជាជនទាំងឡាយ ដែលគេធ្វើការរួមគ្នា ដើម្បីសំរេចការងាររបស់គេ។ ឧទាហរណ៍ដូចជា សមាគមមាតាបិតាសិស្ស សមាគមបុណ្យសព សមាគមរៀបចំអាពាហ៍ពិពាហ៍ និងគណៈកម្មការវត្តជាដើម។

## *ក្រុមជួយខ្លួនឯង. លើសពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចទៅទៀត*

ក្រុមជួយខ្លួនឯង គឺជាអង្គការប្រជាជនដ៏សំខាន់ នៅក្នុងគំរូអភិវឌ្ឍន៍សហគមន៍ចំរុះ អង្គការប៉ាដិក។ គំរូនេះសាងសង់ឡើង ដោយមានក្រុមទាំងនេះជាមូលដ្ឋាន ហើយគឺតាមរយៈក្រុមទាំងនេះ ដែលអន្តរាគមន៍អភិវឌ្ឍន៍នានា ត្រូវបានសំរបសំរួលឡើង។

ក្រុមជួយខ្លួនឯង គឺជាអង្គការសង្គមស៊ីវិលតូចៗ ក្នុងនោះសមាជិកដាក់ប្រាក់សន្សំក្នុងមូលនិធិក្រុមដែលពួកគេអាចខ្ចីមកប្រើប្រាស់ តាមតំរូវការអភិវឌ្ឍន៍ក្នុងគ្រួសារពួកគេ។ ក្រុមបង្កើតច្បាប់ជាច្រើន រួមទាំងកំរិតនៃប្រាក់សន្សំ អត្រាការប្រាក់ដែលសមាជិកត្រូវសងមកក្រុម និងរយៈកាលនៃការប្រជុំក្រុម។ សមាជិកក្រុមទាំងអស់ត្រូវចូលរួម ក្នុងការអនុមត័ប្រាក់កំចី ទៅសមាជិកផ្សេងៗទៀត នៅក្នុងក្រុមរបស់ខ្លួន។

*លើសអីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចទៅទៀត*

ក្រុមជួយខ្លួនឯង ទាំងឡាយស្ថិតនៅថ្នាក់មូលដ្ឋានភូមិ។ ការប្រជុំមានជាញឹកញាប់ ហើយពីមួយពេលទៅមួយពេលសមាជិកក្រុម បានស្គាល់គ្នាកាន់តែច្បាស់ឡើងៗ។

សមាជិកក្រុម គឺជាអ្នករស់នៅជិតខាងគ្នា និងមានសេចក្តីសង្ឃឹមរួមគ្នា សំរាប់អនាគតសហគមន៍របស់ពួកគេ។

នៅក្នុងក្រុមជួយខ្លួនឯង ទស្សនៈនានាដូចជា ការទទួលខុសត្រូវ តំលាភាព បានក្លាយជាការអនុវត្តជាក់ស្តែង មិនមែនជាពាក្យនិយាយតែមាត់នោះទេ។ អ្នកដឹកនាំដែលសមាជិកបោះឆ្នោតជូន ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាកំណត់ហេតុ និងកំណត់ហិរញ្ញវត្ថុរបស់ក្រុម ឱ្យបានត្រឹមត្រូវព្រមទាំងជាដំណាងដល់អត្ថប្រយោជន៍រួមរបស់សមាជិកទាំងអស់ក្នុងករណីចាំបាច់។ ការមានផ្លាស់ប្តូរវេនគ្នាទទួលភារៈកិច្ចជាអ្នកដឹកនាំក្រុម គឺជាការធានាឱ្យមានការផ្តល់អំណាចទូលំទូលាយ ដល់សមាជិកក្នុងក្រុមទាំងមូល។

បន្ថែមលើការពិភាក្សា អំពីផ្នែកហិរញ្ញវត្ថុក្រុមជួយខ្លួនឯង គឺជាយន្តការមួយសំរាប់ពិភាក្សាអំពីបញ្ហាអភិវឌ្ឍន៍ និងកង្វល់មួយចំនួនដែលពាក់ពន្ធ័ជាមួយសមាជិកក្រុមនិងសហគមន៍របស់គេ។ ការប្រជុំនេះពង្រីកការយល់ដឹង របស់សមាជិកក្រុមបន្ថែមទៀត ដូចជា សមភាពផ្នែកយែនឌ័រ ការការពារបរិស្ថាន សិទ្ធិមនុស្ស និងចំណេះដឹងផ្សេងៗទៀត អំពីការផ្សព្វផ្សាយកសិកម្មជាដើម។ ការប្រជុំពិភាក្សាទាំងឡាយត្រូវបាន ដឹកនាំដោយប្រធានក្រុម ឬអ្នកឯកទេសថ្នាក់ភូមិ ឬមានការអញ្ជើញដំណាងអង្គការ ផ្សេងៗ ឬបុគ្គលិកអង្គការប៉ាដិកជាដើម។




## ត្រួតពិនិត្យដើម្បីមានតំលាភាព

តួអង្គទាំងឡាយ នៅក្នុងគំរូអភិវឌ្ឍន៍សហគមន៍ចំរុះ ជាអ្នកទទួលខុសត្រូវ ចំពោះមុខសហគមន៍របស់គេ។ ដំណើរការប្រជាធិបតេយ្យ មិនអាចធានា ថាមិនលំអៀងបានទេ

(តទៅទំព័រទី៦)

### វាមិនមែនជាដំណើរការអភិវឌ្ឍន៍ដែលមានភាពងាយស្រួលទេ...

*ក្នុងពេលថ្មីៗនេះប៉ាដិកបានធ្វើការអង្កេត សមាជិកក្រុមជួយខ្លួនឯងទាំងឡាយនៅក្នុងតំបន់ គាំទ្ររបស់ខ្លួនទាំងប្រាំ។ ចម្លើយបានកំណត់នូវបញ្ហាសំខាន់ៗប្រាំមួយខាងក្រោមនេះដែលទាក់ទិននិងលទ្ធភាពដំណើរការ និងនិរន្តរភាពរបស់ក្រុមជួយខ្លួនឯងនៅពេលអនាគត :*

*-អក្ខរភាព និងជំនាញគិតលេខ ដែលត្រូវឱ្យមានការពង្រឹងបន្ថែម ។*

*-ជំនាញខាងផ្នែកកត់ត្រាបញ្ជី ត្រូវពង្រឹងបន្ថែម*

*-សមាជិកក្រុមខ្លះពុំបានគោរពតាមច្បាប់ក្រុមរបស់ខ្លួន។*

*-ភ្នាក់ងារសំរបសំរួលការងារអភិវឌ្ឍន៍ សហគមន៍សកម្មពេកនៅពេលប្រជុំក្រុម ។*

*-អ្នកដឹកនាំក្រុមភូមិមិនបានប្តូរវេនគ្នា ។មនុស្សដដែលៗបានឈរឈ្មោះនិងត្រូវគេបោះឆ្នោតឱ្យ ។*

*-តើក្រុមនិងទទួលប្រាក់ឥណទានដូចជាទុនបន្ថែមពីទីណានៅពេលដែលប៉ាដិកដកខ្លួនចេញនោះ ។*

[illegible]

[illegible]

ទួនាទីប្រហាក់ប្រហែលគ្នាមាននៅកំរិតឃុំផងដែរតាមរយៈ សមាគមក្រុមជួយខ្លួនឯងថ្នាក់ឃុំ។ បន្ថែមលើនេះទៀត សមាគមក្រុមជួយខ្លួនឯងថ្នាក់ឃុំ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំធ្វើ មហាសន្និបាតប្រជាពលរដ្ឋប្រចាំឆ្នាំ។

### ការទទួលខុសត្រូវរួមគ្នា

ទុនបន្ថែម គឺជាទុនកំចីមិនយកការប្រាក់ ដែលអង្គការប៉ាដិកផ្តល់ ឱ្យក្រុមជួយខ្លួនឯងទាំងឡាយណា ដែលអាចដំណើរការដោយខ្លួនឯងបានល្អ។ ប្រាក់កំចីនេះបង្កើនទុនរបស់ក្រុមសំរាប់សមាជិក អាចប្រើប្រាស់ធ្វើជាដើមទុនសំរាប់គំរោងអភិវឌ្ឍន៍របស់ខ្លួន។ សមាជិកទាំងអស់ ត្រូវតែចូលរួមសំរេចចិត្តឱ្យសមាជិកខ្ចី ហើយក៏ទទួលខុសត្រូវក្នុងការសងមកវិញផងដែរ។ ការរួមចំណែកទទួលខុសត្រូវក្នុងការសង នេះគឺជាមធ្យោបាយមួយឱ្យសមាជិកគ្រប់គ្នាដឹងពីគំរោង ហើយរួមចំណែក ជំរុញឱ្យគំរោងនោះដំណើរការល្អ ។

ឧទាហរណ៍: ស្ត្រីម្នាក់បានទទួលប្រាក់កំចីដើម្បីយកទៅចិញ្ចឹមជ្រូក។ សមាជិកក្រុមទាំងអស់ចង់ឃើញ គំរោងចិញ្ចឹមជ្រូករបស់គាត់បានជោគជ័យ ពីព្រោះសមាជិកទាំងអស់ត្រូវជួយចេញសងជូសគាត់ ក្នុងករណីគាត់ទទួលបរាជ័យ។ ដោយសារភ្នាក់ងារបសុព្យាបាលថ្នាក់ភូមិ (មើលទំព័រទី ១៣) នៅក្នុងក្រុមជួយខ្លួនឯងដែរនោះ គាត់មានឱកាសច្រើន ក្នុងការផ្តល់យោបល់ដល់ស្ត្រីនោះអំពីការចិញ្ចឹមជ្រូក។

នៅឆ្នាំ ២០០២ អង្គការប៉ាដិកបានផ្តល់ទុនបន្ថែមដល់ ២៤១ក្រុមជួយខ្លួនឯង នៅក្នុងតំបន់គាំទ្រទាំងប្រាំ។



*ប្រជុំក្រុមជួយខ្លួនឯងដើម្បីធ្វើការសំរេចចិត្តរួមគ្នាក្នុងការផ្តល់ទុនកំចី*

[illegible]

ក្នុងការសំរបសំរួល ដែលមានតែម្នាក់ឯងនោះ។ សមាជិកដែលបានជាប់ឆ្នោត ជាគណៈកម្មការ អាចដើរខុសគន្លង។ ដូច្នេះចាំបាច់ត្រូវតែកសាងយន្តការត្រួតពិនិត្យនៅក្នុងគំរូនេះផងដែរ។ សមាគមក្រុមជួយខ្លួនឯងថ្នាក់ភូមិ និងឃុំ ជាអ្នកទទួលខុសត្រូវចំពោះដំណើរការនេះ។

មនុស្សម្នាក់ មកពីក្រុមជួយខ្លួនឯងនិមួយៗ នៅក្នុងភូមិត្រូវបានជ្រើសរើសជាដំណាង របស់សមាគមក្រុមជួយខ្លួនឯងថ្នាក់ភូមិ។ សមាគមក្រុមជួយខ្លួនឯងថ្នាក់ភូមិ ធ្វើការជាមួយអង្គការប្រជាជនផ្សេងៗទៀតនៅក្នុងភូមិ ដើម្បីត្រួតពិនិត្យមើលការអនុវត្ត របស់អ្នកសំរបសំរួល (មើលទំព័រ១០)។ អ្នកដឹកនាំសមាគមក្រុមជួយខ្លួនឯងថ្នាក់ភូមិ ចូលរួមគ្រប់កិច្ច ប្រជុំអ្នកដឹកនាំភូមិ។

### ក្រុមជួយខ្លួនឯង -ជាសក្តានុពល សំរាប់ការផ្លាស់ប្តូរ

ការប្រជុំដោយទៀងទាត់នឹងញឹកញាប់ ដែលក្រុមជួយខ្លួនឯងត្រូវឱ្យមាន ជាយានសំរាប់ឱ្យប្រជាជនស្គាល់គ្នាទៅវិញទៅមក ដើម្បីឱ្យពួកគេបង្ហាញនូវបញ្ហា និងសេចក្តីប្រាថ្នារបស់ខ្លួន និងបង្កើតបាននូវទស្សនៈរួមមួយ ថាតើគេចង់ឃើញសហគមន៍គេ មានការប្រែប្រួលយ៉ាងណាទៅថ្ងៃអនាគត។

កិច្ចប្រជុំក្រុមជួយខ្លួនឯងជួយបំប៉នគំនិតនិងគុណតំលៃនៃលទ្ធិប្រជាធិបតេយ្យ ភាពទទួលខុសត្រូវតំលាភាព សាមគ្គីភាពយុត្តិធម៌សង្គម ហើយសំខាន់ជាងនេះទៅទៀត ធ្វើឱ្យគេមានជំនឿលើខ្លួនគេនៅក្នុងសហគមន៍។

ចំពោះស្ត្រីវិញក្រុមជួយខ្លួនឯង គឺជាវេទិកាដើម្បីអោយពួកគេបានទទួលនូវបទពិសោធន៍ ក្នុងការបញ្ចេញមតិ បញ្ចេញគំនិតផ្តួចផ្តើម រៀនសូត្រពីច្បាប់ទំលាប់ ក្រុមបំពេញមុខងារពេញលេញ និងចូលរួមយ៉ាងសកម្មភាពនៅក្នុងសហគមន៍។ ទាំងអស់នេះជួយឱ្យស្ត្រីមានលទ្ធភាព រៀបចំខ្លួនចូលរួមក្នុងវេទិកាធំៗផ្សេងៗទៀត។

ការសំរបសំរួលបង្កើតក្រុមជួយខ្លួនឯងគឺជាសកម្មភាពចាប់ផ្តើម របស់អង្គការប៉ាដិក នៅក្នុងសហគមន៍។ ការអនុវត្តដូចនេះបង្ហាញសហគមន៍ឱ្យឃើញនូវសក្តានុពលនៃការប្រែប្រួល នៅពេលណាប្រជាជនធ្វើការរួមគ្នាព្រមទាំងការពិតមួយដែលថាបុគ្គល អាចបង្កើនប្រាក់ចំណេញរបស់ខ្លួនតាមរយៈកិច្ចសហប្រតិបត្តិការជាមួយអ្នកដទៃទៀត។

## ស្តាប់សំដីអ្នកក្រីក្រ

មហាសន្និបាតប្រជាពលរដ្ឋ គឺជាការជួបជុំគ្នារវាងប្រជាជននិងអ្នកដំណាងរបស់គេនៅថ្នាក់ឃុំ ។ អ្នកដែលត្រូវបានអញ្ជើញ ចូលរួមមានអ្នកដឹកនាំសហគមន៍ អាជ្ញាធរដែនដី រាជរដ្ឋាភិបាល ថ្នាក់ស្រុក ខេត្ត អង្គការមិនមែនរដ្ឋាភិបាលនានា អ្នកផ្តល់ជំនួយ និងសមាជិកអង្គការសង្គមស៊ីវិលផ្សេងទៀត ។

មហាសន្និបាត ផ្តល់វេទិកាឱ្យប្រជាពលរដ្ឋ នៅក្នុងឃុំ សំដែងមតិដែលជាកង្វល់ និងជាសេចក្តីប្រាថ្នារបស់គេ ។ មហាសន្និបាតប្រជាពលរដ្ឋ គឺជាការតស៊ូមតិមួយ ដែលប្រជាជនអាចបញ្ចេញយោបល់តទល់គ្នា ដែលក្នុងនោះប្រជាជនចូលរួមដោយភាពទុកចិត្តគ្នា ។

ជាទូទៅអ្នកចូលរួម គឺជាដំណាងប្រជាជនទាំងអស់ នៅក្នុងឃុំ មានតួនាទី បញ្ចេញសកម្មភាពជូនប្រជាជន ។ ក្នុងមហាសន្និបាតនេះ ប្រជាជនបាន អញ្ជើញដំណាងសហគមន៍ ធ្វើរបាយការណ៍ អំពីការរីកចំរើន ឬការខ្វះខាតកន្លងមក ។ ធ្វើដូច្នោះ គេអាចជួយផ្តល់យោបល់បំពេញបន្ថែមក្នុងកិច្ចការឃុំ ។

ការសំរបសំរួលឱ្យមានមហាសន្និបាតប្រជាពលរដ្ឋថ្នាក់ឃុំ គឺជាឧទាហរណ៍មួយនៃការព្យាយាមរបស់អង្គការប៉ាដិក ក្នុងការលើកទឹកចិត្ត ការពិគ្រោះយោបល់ ជាពិសេសរវាងប្រជាជន និងរដ្ឋាភិបាល ។ តួនាទីរបស់ប៉ាដិក គឺបកស្រាយបញ្ហាទាំងឡាយ ដែលលើកមកពិភាក្សាគ្នា នៅក្នុងមហាសន្និបាត និងនាំបញ្ហាទាំងនោះទៅតស៊ូមតិនៅថ្នាក់ជាតិ ។ អង្គការប៉ាដិកដើរតួនាទីនេះរហូតដល់ពេលណាដែលប្រជាជន អាចម្ចាស់ការធ្វើបានដោយខ្លួនគេ ។

ធ្វើដូចនេះ យើងសង្ឃឹមថានឹងជំរុញឱ្យមានដំណើរការគន្លឹះដែលឆ្លើយតបទៅ នឹងបញ្ហានានារបស់អ្នកក្រីក្រ នៅថ្នាក់គោលនយោបាយជាតិ ។

*វេទិកាមួយដើម្បីស្តាប់អ្នកក្រីក្រនិយាយៈ មហាសន្និបាតប្រជាពលរដ្ឋនៅឃុំជាខ្លាង*



*ដំណាងស្រ្តី បញ្ចេញមតិ សំដែងកង្វល់ របស់គេ ក្នុងមហា សន្និបាតប្រជា ពលរដ្ឋ នៅ ឃុំ[illegible]*

### បញ្ហាទាំងឡាយដែលបានលើកឡើងដោយអ្នកក្រីក្រ

[illegible] ឆ្នាំ១៩៩៨ [illegible] មហាសន្និបាត [illegible] ចំនួន១៣ [illegible] អង្គការប៉ាដិក ។

**បញ្ហាទាំងឡាយដែលបានលើកឡើងរួមមាន**

-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]

**សំណូមពរជួយដោះស្រាយ រួមមានៈ**

-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]
-[illegible]

## ផ្តល់លទ្ធភាពចំពោះសំឡេង អ្នកក្រីក្រ

រៀបចំមហាសន្និបាតប្រជាពលរដ្ឋគឺជាការងារដ៏ធំមួយ។ វាជាការទទួលខុសត្រូវ របស់គណៈកម្មការក្រុមជួយខ្លួនឯងឃុំ ដោយបង្កើតអោយមានអង្គប្រជុំពិភាក្សាគ្នាតាមភូមិ នៅក្នុងឃុំរបស់ខ្លួនដើម្បីកំណត់នូវកង្វល់ទាំងឡាយ ហើយធានាថាកង្វល់ទាំងនោះ និងយកមកលើកឡើងនៅក្នុង អង្គមហាសន្និបាតប្រជាពលរដ្ឋ។

ថ្វីបើការងារនេះមានការលំបាកពិតមែន តែទាំងអស់គ្នាឯកភាពថា ជាការងារមានតំលៃមួយដែលត្រូវអនុវត្ត:

- "*ខ្ញុំមិនដែលឃើញមុខរដ្ឋាភិបាលទេទើបតែពេលនេះ*" ប្រសាសន៍អ្នកភូមិ។
- "*ជូនកាលបញ្ហាខ្លះដែលលើកឡើងដោយអ្នកភូមិ ក្នុងពេលប្រជុំរៀបចំ ជាបញ្ហាតូច ហើយយើងអាចដោះស្រាយជូនគេបាន នៅក្នុងកិច្ចប្រជុំនោះតែម្តង តែបញ្ហាខ្លះទៀតធំៗ និងសំខាន់ៗ ដែលមានតែរដ្ឋាភិបាលទេទើបអាចដោះស្រាយបាន ដូច្នេះបញ្ហាទាំងនេះ ត្រូវនាំយក ទៅដាក់ក្នុងរបៀបវារៈនៃអង្គមហាសន្និបាត*" ប្រសាសន៍ ប្រធានសមាគមក្រុមជួយខ្លួនឯងឃុំ។
- "*មហាសន្និបាតប្រជាពលរដ្ឋ គឺផ្តល់លទ្ធភាពជូនប្រជាជន ដើម្បីប្រើប្រាស់សិទ្ធិបញ្ចេញមតិរបស់គេដូចបានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា*" ប្រសាសន៍អភិបាលខេត្ត។
- "*នេះជាលើកទីពីរហើយដែលខ្ញុំបានចូលរួមប្រជុំមហាសន្និបាតប្រជាពលរដ្ឋ នេះជាអង្គប្រជុំដ៏ល្អ ពីព្រោះបានផ្តល់ឱ្យប្រជាជននៅជនបទដាច់ស្រយាល មានឱកាសបានសំដែងនូវកង្វល់ទាំងឡាយ របស់គេអោយអាជ្ញាធរបានដឹង និងទាមទារសុំជួយស្វែងរកដំណោះស្រាយ យ៉ាងសមស្របឱ្យពួកគាត់*" ប្រសាសន៍បញ្ជាការយោធាស្រុក។
- "*ប្រជាជនបានលើកឡើងបញ្ហាជាច្រើន មហាសន្និបាតគួរតែមានរយៈពេលបីថ្ងៃ*" ប្រសាសន៍អ្នកសំរបសំរួលអភិវឌ្ឍន៍សហគមន៍ របស់អង្គការប៉ាដិក។
- "*ពេលត្រឡប់ទៅវិញ ខ្ញុំនិងប្រាប់អ្នកភូមិខ្ញុំអោយគេបានដឹងនូវអ្វីដែលខ្ញុំបានឮក្នុងថ្ងៃនេះ*" ប្រសាសន៍អ្នកភូមិ។

## ស្តាប់សំដីអ្នកក្រីក្រ,,,,

ក្នុងឆ្នាំ១៩៩៩ មហាសន្និបាតប្រជាពលរដ្ឋមួយបានរៀបចំឡើងនៅឃុំជាខ្លាង ស្រុកព្រៃវែង ខេត្តព្រៃវែង។ ក្នុងឱកាសនោះអ្នកចូលរួមមានរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលខេត្តព្រៃវែង អភិបាលស្រុកព្រៃវែង ប្រធានមន្ទីរ និងការិយាល័យជំនាញ ខេត្ត ស្រុក សមាជិកសហគមន៍ និងបុគ្គលិកអង្គការប៉ាដិកផងដែរសរុបជាងបីរយនាក់បានចូលរួម។ ពីរ បីសប្តាហ៍មុនមហាសន្និបាត ប្រជាជនឃុំជាខ្លាងបានជួបគ្នាជាច្រើនដង ដើម្បីពិភាក្សាអំពីបញ្ហា និងកង្វល់ទាំងឡាយ របស់ពួកគេដែលគេមានបំណងនាំយកទៅ ថ្លែងជាផ្លូវការជំរាបអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ដើម្បីចូលរួមជួយដោះស្រាយឱ្យពួកគេ។ នៅថ្ងៃប្រមហាសន្និបាត ប្រជាជនបានបង្ហាញកង្វល់ទាំងនេះជូនអាជ្ញាធរព្រមទាំងកំណត់ ជាលាយលក្ខណ៍អក្សរ និងរៀបចំជាតារាងបានយ៉ាងល្អប្រសើរ។

ពីរបីខែកន្លងមក ក្នុងនាមជាតំណាងរបស់ប្រជាជន អង្គការប៉ាដិកបានទទួលលិខិតមួយច្បាប់ ពីទេសរដ្ឋមន្ត្រីទីស្តីការក្រុមប្រឹក្សារដ្ឋមន្ត្រីផ្ញើជូនក្រសួងពាក់ពន្ធ័ក្នុងជួររដ្ឋាភិបាល។ លិខិតរបស់ប្រជាជនខេត្តព្រៃវែងត្រូវបានភ្ជាប់ និងមានចំណារបញ្ជាក់ ឱ្យក្រសួងពាក់ពន្ធ័ទាំងឡាយគប្បីពន្យល់ និងផ្សព្វផ្សាយគោលនយោបាយរបស់រដ្ឋាភិបាលដល់ប្រជាជន។

*មហាសន្និបាតប្រជាពលរដ្ឋនៅឃុំមេបុណ្យ*

នៅខែមករាឆ្នាំ ២០០៣ មហាសន្និបាតប្រជាពលរដ្ឋមួយ បានរៀបចំឡើងនៅក្នុងឃុំមេបុណ្យស្រុកព្រៃវែង ខេត្តព្រៃវែង។ ជាកិច្ចចាប់ផ្តើមអ្នកដឹកនាំអង្គការសហគមន៍មូលដ្ឋានធ្វើរបាយការណ៍ អំពីស្ថានភាពសហគម៍ន៍របស់គាត់កន្លងមក។ រយៈកាលជិតដប់ឆ្នាំមកហើយ ដែលអង្គការប៉ាដិកបានធ្វើការជាមួយសហគមន៍របស់ឃុំនេះ។

តាមរបាយការណ៍បច្ចុប្បន្ននេះ ប្រជាជនក្នុងឃុំមានស្ថានភាពប្រសើរជាងមុន។ ជាការប៉ាន់ប្រមាណ នៅឆ្នាំ១៩៩៧ ទូរទស្សន៍មួយគ្រឿង ត្រូវប្រើប្រាស់បីគ្រួសារ។ នៅឆ្នាំ ២០០២ បរិ មាណទូរទស្សន៍នៅទូទាំងឃុំ បានកើនឡើង ៥០ភាគរយ។ ចំណែកវិទ្យុវិញ បច្ចុប្បន្នពីរគ្រួសារមានវិទ្យុមួយគ្រឿង បើប្រៀបធៀបទៅឆ្នាំ១៩៩៧ គឺវិទ្យុមួយប្រើសំរាប់ប្រាំគ្រួសារ។

នៅកំរិតឃុំ បន្ទុកការងាររបស់ស្ត្រី បានត្រូវកាត់បន្ថយយ៉ាងច្រើន ដោយមានការកើនឡើងនូវមធ្យោបាយប្រើប្រាស់ សំរាប់ស្រោចស្រព និងបូមបាច។ នៅឆ្នាំ ២០០២ ក្នុងឃុំមាន ម៉ាស៊ីនបូមទឹកចំនួន ១៨២ គ្រឿង ដែលកាលពីឆ្នាំ ១៩៩៧ មានត្រឹមតែ៩២ គ្រឿង។ ជាមួយគ្នានោះម្ភៃគ្រួសារប្រើប្រាស់ម៉ាស៊ីនកិនស្រូវខ្នាតតូចមួយ ដែលកាលពីឆ្នាំ ១៩៩៧ ម៉ាស៊ីនកិន ស្រូវមួយសំរាប់៤០គ្រួសារ។ នេះក៏ជាការកាត់ បន្ថយបន្ទុកការងាររបស់ស្ត្រី ក្នុងការកិនស្រូវសំរាប់បរិភោគក្នុងគ្រួសារ។

គណៈកម្មការ អង្គការសហគមន៍មូលដ្ឋានបានមានប្រសាសន៍ថា ទោះជាយ៉ាងណាក៏ដោយ ក៏ស្ថានភាពទាំងមូលក្នុងភូមិមិនបានល្អប្រសើរទាំងអស់នោះដែរ។ គ្រួសារប្រជាជនដែលមានផ្ទះសំបែង បានថយចុះពី៩៨% នៅឆ្នាំ១៩៩៧ មក៩៧% នៅឆ្នាំ ២០០២។ ជាងនេះទៅទៀតគ្រួសារឥតដីធ្លី ដែលមិនធ្លាប់មានពីមុនមកពេលបច្ចុប្បន្ននេះមាន៥០គ្រួសារឥតមានដីធ្លីស្មើនិង ២ភាគរយ។

*(តទៅទំព័រទី៩)*



*ថ្នាក់អក្ខរកម្មនៅសហគមន៍*

### *លទ្ធផលទទួលបានពីៈ មហាសន្និបាតប្រជាពលរដ្ឋ នៅឃុំស្វាយចេក*

កាលពីដើមឆ្នាំ២០០២ យោធាមួយក្រុម បានចូលកាន់កាប់ដីប្រហែលជាង៩០០ហិកតា ជាដីផលិតដំណាំកសិកម្ម របស់ប្រជាជនចំនួនជាង ២០០គ្រួសារ នៅក្នុងភូមិពីររបស់ឃុំស្វាយចេក ដីនេះ ពួកគាត់ធ្លាប់បានកាន់កាប់មកតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។ ជាបណ្តើរៗ ប្រជាជនបាននាំគ្នាដកបង្គោល ដែលបោះពទ្ធ័ជុំវិញដីនោះ ហើយធ្វើការតវ៉ាទៅមេភូមិ ពីការរំលោភយកដីរបស់គាត់នេះ ។ តែពួកគាត់មិនបានទទួលដំណោះស្រាយជាលទ្ធផលអ្វីឡើយ ។

អង្គការប៉ាដិក ចាប់ផ្តើមធ្វើការនៅក្នុងឃុំស្វាយចេក នៅកំឡុងកាលដែលជំនាស់ដីធ្លីនេះបានកើតឡើង។ អង្គភាពគាំទ្រតំបន់របស់ អង្គការប៉ាដិក ជាមួយប្រជាជន បានរៀបចំមហាសន្និបាតប្រជាពលរដ្ឋមួយ ក្នុងខែធ្នូឆ្នាំ ២០០២ នៅសៀមរាប ។

មុនថ្ងៃមហាសន្និបាត បញ្ហារាយបញ្ហា និងកង្វល់នានាដែលប្រជាជនត្រូវលើកឡើងក្នុងអង្គប្រជុំបានត្រូវ ចែកជូនដល់មន្ត្រីរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលផ្សេងៗ ដែលអញ្ជើញមកចូលរួមក្នុងអង្គប្រជុំនេះ។ ជាការពិតណាស់ ទំនាស់ដីធ្លីនៅឃុំស្វាយចេកជាបញ្ហាមួយសំខាន់ ក្នុងរបៀបវារៈនេះផងដែរ ។

មន្ត្រីម្នាក់ដែលទទួល របៀបវារៈនេះជា អភិបាលស្រុកថ្មីទើបនឹងមកកាន់ដំណែងនេះ។ គាត់ជាមនុស្សសកម្មហើយភ្លាមៗនោះ គាត់បានទៅជួបទាក់ទងផ្ទាល់ជាមួយនិងនាយទាហាន ដើម្បីចរចាយកដីនោះមកជូនប្រជាជនវិញ ហើយនាយទាហានទាំងនោះ ក៏ឯកភាពតាមសំណូមពររបស់គាត់។ មុនពេលធ្វើ មហាសន្និបាតប្រជាពលរដ្ឋមួយថ្ងៃ ទំនាស់ដីធ្លីនេះ ត្រូវបានបញ្ចប់ដោយដីនេះ ត្រូវបានប្រគល់ជូនមកប្រជាជនវិញ។

បញ្ហាមួយចោទឡើង ថាតើយោធានឹងទៅកាន់កាប់ដីនៅទីណាទៀត។ ទោះជាយ៉ាងណាក៏ដោយបទពិសោធន៍ របស់ប្រជាជននៅឃុំស្វាយចេកនេះជាឧទាហរណ៍ ជាក់ស្តែងមួយបង្ហាញអំពីសក្តានុពលនៃការដោះស្រាយទំនាស់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ នៅក្នុងវេទិកាអព្យាក្រឹតមួយ ដូចការរៀបចំមហាសន្និបាតប្រជាពលរដ្ឋនេះ។ នេះជាភារកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តួចផ្តើមវេទិកាបែបនេះ សំរាប់ការពិគ្រោះយោបល់រហូត ដល់ពេលណាមួយដែលប្រជាជនតាមរយៈសង្គមស៊ីវិលនានា អាចស្វែងរកនិងធានាឱ្យមានឱកាស សំរាប់បង្កើតអង្គប្រជុំបែបនេះដោយខ្លួនគេផ្ទាល់។ ✿



*ឯកឧត្តម* ***យ៉េន លីម ស្រៀង*** *អភិបាលរងខេត្តសៀមរាបចូលរួមដោះស្រាយបញ្ហានិងកង្វល់ជូនប្រជាជនក្នុងមហាសន្និបាតប្រជាពលរដ្ឋឆ្នាំ២០០២ នៅឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប*



*ការថែទាំ និងដាំព្រៃឈើសារជាថ្មីឡើងវិញ*



# ៤~អ្នកសំរបសំរួល

## គណៈកម្មការអភិវឌ្ឍន៍ភូមិ (គអភ) និង គណៈកម្មការអភិវឌ្ឍន៍ឃុំ (គអឃ) ធ្វើការរួមគ្នាដើម្បីផ្លាស់ប្តូរ




អ្នកសំរបសំរួល បានជ្រើសរើសចេញពីការបោះឆ្នោតដោយប្រជាធិបតេយ្យ ដើម្បីសំរបសំរួលការងារអភិវឌ្ឍន៍។ គេជាអ្នកទទួលខុសត្រូវដើម្បី ធានាកំណត់តំរូវការសហគមន៍ ហើយបង្កើតជាផែនការអភិវឌ្ឍន៍ ដែលបានមកពីការពិភាក្សានិង ការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់រូប។

នៅក្នុងគំរូអភិវឌ្ឍន៍សហគមន៍ចំរុះអង្គការប៉ាដិកធ្វើការ ជាមួយក្រុមអ្នកសំរបសំរួលពីរប្រភេទគឺ -គណៈកម្មការអភិវឌ្ឍន៍ភូមិ (គអភ) ក្នុងកំរិតភូមិ និងគណៈកម្មការអភិវឌ្ឍន៍ឃុំ (គអឃ) ក្នុងកំរិតឃុំ។មនុស្សពេញវ័យគ្រប់ៗគ្នា នៅក្នុងភូមិអាចឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោតឱ្យ និងទៅបោះឆ្នោតដើម្បីជ្រើសរើសយក បេក្ខជន៥នាក់ សំរាប់ដំណែងជា គ អ ភ។ គ អ ឃ ជាអ្នកដឹកនាំចេញមកពីប្រធាន គ អ ភ នៅក្នុងឃុំ ។ ដើម្បីធ្វើការងារឱ្យបានល្អប្រសើរនោះ ប៉ាដិកធ្វើការជាមួយគ្រប់ ភូមិទាំងអស់នៅក្នុងឃុំ។

*កំរិតភូមិ*

គ អ ភ ជាអ្នកសំរបសំរួលប្រជុំអាណត្តិអ្នកដឹកនាំភូមិ ជាមួយនឹងអ្នកដឹកនាំសំខាន់ៗផ្សេងទៀតនៅក្នុងភូមិរបស់គេ។ អ្នកចូលរួមប្រជុំ រួមមានប្រធានភូមិ អ្នកដឹកនាំសមាគមក្រុមជួយខ្លួនឯងភូមិ តំណាងអ្នកឯកទេសថ្នាក់ភូមិ សមាជិកក្រុមប្រឹក្សាឃុំ ព្រះសង្ឃ នឹងចាស់ព្រឹទ្ធាចារ្យក្នុងភូមិ។

ក្នុងនាមតំណាងឱ្យប្រជាជន ដែលជ្រើសរើសដោយការបោះឆ្នោត គាត់ជាអ្នកទទួលខុសត្រូវណែនាំ ធ្វើផែនការដោយមានការពិគ្រោះយោបល់ ហើយធានាថាបញ្ហាទាំងឡាយ ត្រូវបានយកចិត្តទុកដាក់ពិភាក្សាគ្នាយ៉ាងទូលំទូលាយ។ គាត់ត្រូវមានឧត្តមគតិ និងយកចិត្តទុកដាក់ជាពិសេស ដល់សមាជិកសហគមន៍ក្រីក្របំផុតដើម្បីឱ្យសំឡេងរបស់ពួកគេបានឮផងដែរ។

*...តឃុំ*

ការងារអភិវឌ្ឍន៍ភូមិ ឧទាហរណ៍ការជួសជុលថ្នល់ក្នុងភូមិ ការតស៊ូមតិដើម្បីកសាងសាលារៀន ការរៀបចំរំលឹកទិវានារីអន្តរជាតិ តំរូវអោយមានការសំរបសំរួលរវាងភូមិនានានៅក្នុងឃុំ។ ក្នុងករណីនេះ គអឃ សំរបសំរួលប្រជុំអណត្តិជាមួយ អ្នកដឹកនាំឃុំផ្សេងៗទៀតដើម្បីធ្វើផែនការ និងត្រួតពិនិត្យកិច្ចសហប្រតិបត្តិការរវាងភូមិទាំងនោះ។

គអឃ ណែនាំសហគមន៍ ក្នុងការប្រមែប្រមូលធនធានផ្សេងៗ ក្នុងមូលដ្ឋានរបស់គេមាន ពេលវេលា កម្លាំងពលកម្ម សំភារៈ និងហិរញ្ញវត្ថុ ដើម្បីឈានទៅសំរេច នូវគំរោងនានារបស់សហគមន៍។ នៅពេលគំរោងផែនការណាមួយ មិនអាចសំរេចបានដោយគ្មានជំនួយឧបត្ថម្ភពីខាងក្រៅនោះ គអឃ ទទួលខុសត្រូវ ទំនាក់ទំនងរកប្រភពជំនួយ ដូចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតដើម្បី ប្រមែប្រមូលធនធាន បំពេញសេចក្តីត្រូវការទាំងនោះ។

*ការបង្កើនសម្ថភាព*

ប៉ាដិកមានមុខងារបង្កើនសមត្ថភាពរដ្ឋបាល និងគ្រប់គ្រង របស់សមាជិក គអភ និង គអឃ តាមរយៈការហ្វឹកហ្វឺនជំនាញផ្សេងៗ រួមមានភាពជាអ្នកដឹកនាំ ការសំរបសំរួលអង្គប្រជុំ ជំនាញខាងទំនាក់ទំនង ការសរសេរសំណើរ

(តទៅទំព័រទី១១)



*ការប្រជុំរបស់អ្នកដឹកនាំ អង្គការសហគមន៍មូលដ្ឋាន*

**គអអភ និង គអអយ:** ធ្វើការរួមគ្នា.... គំរោង ការគ្រប់គ្រងគំរោង ការធ្វើផែនការ ការត្រួតពិនិត្យ និងវាយតំលៃ។ វាមានសារៈសំខាន់ណាស់ ដែលអ្នកសំរបសំរួលទាំងឡាយ មានចំណេះដឹងច្បាស់លាស់ និងត្រឹមត្រូវអំពីសិទ្ធិមនុស្ស ការដោះស្រាយទំនាស់ និងសមធម៌ផ្នែកយេនឌ័រ ដែលប៉ាដិកធ្វើដោយខ្លួនឯង ឬអ្នកជំនាញមកពីខាងក្រៅ ដើម្បីផ្តល់ការហ្វឹកហ្វឺនទាំងនេះឱ្យគាត់ក្នុងករណីចាំបាច់។

ដោយ គអភ ត្រូវធ្វើការជាមួយ រចនាសម្ព័ន្ធដែលមានរួចស្រាប់ នៅក្នុងមូលដ្ឋានឧទាហរណ៍ ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់វាមានសារៈសំខាន់ណាស់ ដែលរចនាសម្ព័ន្ធនេះយល់ដឹងនូវទស្សនៈ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់អង្គការប៉ាដិក។ អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ ដែលមានឥទ្ធិពលផ្សេងៗទៀតក៏ត្រូវបានអញ្ជើញចូលរួម ក្នុងវគ្គហ្វឹកហ្វឺនដែលសំរបសំរួល ឡើងសំរាប់ គអភ និង គអយ ។

នៅដំណាច់ឆ្នាំ ២០០១ គអភ និង គអយ ពី ៤០-៥០ ភាគរយ នៅតាមតំបន់និមួយៗ អាចដំណើរការបាន។

*(សូមអាន: លក្ខណៈវិនិច្ឆ័យ ដែលហៅថាអង្គការសង្គមស៊ីវិល អាចដំណើរការបានដូចខាងក្រោម)*

ទាំងអស់នោះ ជាអ្នកសំរបសំរួល ដែលអង្គការប៉ាដិកបានធ្វើការជាមួយ ជាច្រើនឆ្នាំមកហើយ។

✿

**ស្ត្រីមានតួនាទីក្នុង គ.អ.ភ.និង គ.អ.ឃ ពីឆ្នាំ ១៩៩៩-២០០២**

(ភាគរយរបស់សមាជិកគិតជា%)




សំគាល់: គោលនយោបាយយេនឌ័រ របស់ប៉ាដិកបាន ចែងជាលក្ខខណ្ឌថា យ៉ាងហោចណាស់ ៥០% ក្នុងដំណែង ជាអ្នកដឹកនាំសហគមន៍ត្រូវកាន់កាប់ដោយស្ត្រីដែល កំពុងរស់នៅក្នុងសហគមន៍នោះ។

### តើផ្អែកលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដែលថាសង្គមស៊ីវិលមួយ អាចដំណើរការបាន?

*អង្គការប៉ាដិកបានវាយតំលៃអង្គការសង្គមស៊ីវិល ក្នុងគំរូអភិវឌ្ឍន៍សហគមន៍ចំរុះ ថាអាចដំណើរការបានតាមកំណត់ ពីលេខ ០-១០០% ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យប្រាំមួយ ដូចខាងក្រោម:*

*១-លទ្ធភាពក្នុងការសំរបសំរួលអង្គប្រជុំដោយខ្លួនគេ និងធ្វើការសំរេចចិត្តរួមគ្នាដោយប្រជាធិបតេយ្យ។*

*២-លទ្ធភាពរបស់គេក្នុងការលើកផែនការ និងការគ្រប់គ្រងសកម្មភាព អភិវឌ្ឍន៍សហគមន៍ក្នុងបែបបទមួយ ដែលមិនធ្វើឱ្យខូចខាតផលប្រយោជន៍អ្នកផ្សេងទៀត និងមនុស្សជំនាន់ក្រោយ ។*

*៣-លទ្ធភាពគេក្នុងការបំរើសេចក្តីត្រូវការរបស់អ្នកក្រីក្រដោយរាប់បញ្ចូលស្ត្រីភេទនៅក្នុងសហគមន៍។*

*៤-លទ្ធភាពរបស់គេក្នុងការប្រើប្រាស់ធនធានពីក្នុង និងពីក្រៅសហគមន៍ប្រកបដោយ តំលាភាពដើម្បីការងារអភិវឌ្ឍន៍សហគមន៍។*

*៥-លទ្ធភាពរបស់គេ ក្នុងការបណ្តុះស្មារតីសាមគ្គីភាព និងស្មារតីសហគមន៍។*

*៦-លទ្ធភាពរបស់គេក្នុងការងារទំនាក់ទំនង បង្កើតបណ្តាញជាមួយអង្គការ វិស្ថាបន័ដែលមានរូបភាពប្រហាក់ប្រហែលគ្នា ដើម្បីដោះដូរបទពិសោធន៍ និងធ្វើការតស៊ូមតិ។*



*វគ្គហ្វឹកហ្វឺនផ្តល់ជូនដល់ក្រុមអ្នកបណ្តុះបណ្តាលបន្តផ្នែកយេនឌ័រ*
*ដោយអង្គការប៉ាដិក*

# ការដកខ្លួនជាបណ្តើរៗ

ជារៀងរាល់ឆ្នាំប៉ាដិក បង្កើតឱ្យមានកិច្ចប្រជុំមួយរយៈពេលបីថ្ងៃ សំរាប់សំរបសំរួលផែនការយុទ្ធសាស្រ្ត។ ក្រុមអ្នកគ្រប់គ្រងអង្គការប៉ាដិកព្រមទាំងបុគ្គលិក ជួបជុំគ្នាជាមួយ និងគណៈកម្មការអភិវឌ្ឍន៍ឃុំ និងមន្រ្តីរដ្ឋាភិបាលដើម្បីពិភាក្សា អំពីលទ្ធផលរីកចំរើនក្នុងឆ្នាំកន្លងមក និងពិនិត្យសំរេចលើផែនការអនុវត្តសំរាប់ឆ្នាំបន្តទៀត។

នៅឆ្នាំ ២០០១ អង្គការប៉ាដិកបានផ្តង់ស្មារតីទៅលើការ "ដកខ្លួន ជាបណ្តើរៗ" ដោយផ្តល់លទ្ធភាព ឱ្យសហគមន៍គ្រប់គ្រងគំរោងដោយខ្លួនឯង។សមាជិកគណៈកម្មការអភិវឌ្ឍន៍ឃុំពពីស នៅព្រៃវែង បានពន្យល់យ៉ាងក្បោះក្បាយអំពីមូលហេតុ ដែលប៉ាដិកមានបំណងដកខ្លួនជាបណ្តើរៗ។

*"យើងជឿជាក់ថា យើងបានចាប់ផ្តើមកសាងសហគមន៍មួយដែលមាននិរន្តរភាព។ យើងអាចរៀបចំយុទ្ធសាស្រ្ត និងគ្រប់គ្រងការងារអភិវឌ្ឍន៍បានដោយខ្លួនយើងហើយ យើងក៏មានសមត្ថភាពសំរបសំរួលអោយមាន ការបោះឆ្នោតជ្រើសរើសបែបប្រជាធិបតេយ្យ ស្រ្តីនៅក្នុងសហគមន៍យើងបានធ្វើជាដំណាងមានចំនួនល្អប្រពៃ"*

អង្គការប៉ាដិករំពឹងថាដំណើរការដកខ្លួន ជាបណ្តើរៗ និងត្រូវការពេលពី១ ទៅ២ឆ្នាំ *(សូមអាន ការកំណត់ពេលវេលា អនុវត្តគំរូអភិវឌ្ឍន៍សហគមន៍ចំរុះនៅទំព័រ១៨ ដែលរៀបរាប់យ៉ាងពិស្តារ)*

ប៉ាដិកសង្ឃឹមថា សហគមន៍ទាំងឡាយក្នុងចំណោម ២២ឃុំ ដែលអង្គភាពគាំទ្រតំបន់របស់អង្គការប៉ាដិកធ្វើការជាមួយនោះ គេអាចដំណើរការបានដោយខ្លួនគេ ហើយអាចក្លាយជាអង្គការសហគមន៍មូលដ្ឋាន( អសម) ។ អង្គការប៉ាដិក នឹងបន្តពង្រឹងសមត្ថភាព អ ស ម ជាពិសេសបង្កើនការយល់ដឹងរបស់គាត់ អំពីទំនាក់ទំនងកិរិតមីក្រូ-ម៉ាក្រូ នៃបញ្ហានានា ក្នុងសង្គមទំនើប នៃសកលភាវូបនីយកម្មសេដ្ឋកិច្ច កសាងទំនាក់ទំនងជាមួយ និងអង្គការប្រជាជនផ្សេងៗទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍។ ក្នុងបំណងធ្វើឱ្យសកម្មថែមទៀត ក្នុងការដាក់ឥទ្ធិពលលើ ការរៀបចំគោលនយោបាយថ្នាក់ជាតិ។

✿



*វគ្គហ្វឹកហ្វឺន អំពីការគ្រប់គ្រង និងចាត់ចែងគំរោង ផ្តល់ឱ្យអ្នកដឹកនាំសហគមន៍*



*គណៈកម្មការ អភិវឌ្ឍន៍ភូមិ សំរបសំរួលអង្គ[illegible]នៃការប្រចាំឆ្នាំជាមួយ និងអ្នកភូមិ*



*អណ្តូងទឹកស្អាត ដែល[illegible]*



*នេះជាសាលាបឋមសិក្សា នៅភូមិដូនឪ ឃុំលាងដៃ (សៀមរាប)។ ជាសាលាមួយក្នុងចំណោមសាលាទាំង៦ ដែលអង្គការប៉ាដិកបានផ្តល់អោយនៅឃុំនេះ។ មុនឆ្នាំ១៩៩៤ ឃុំនេះមានសាលាតែមួយខ្នង (៣បន្ទប់)*

# ៥_អ្នកឯកទេស

## ជំនាញសំរាប់ការអភិវឌ្ឍន៍

បុគ្គលិកប៉ាដិកនិងអ្នកហ្វឹកហ្វឺនមកពីខាងក្រៅ ធ្វើការដើម្បីកសាងសមត្ថភាព ដល់ ក្រុមជំនាញ ៧ក្រុម នៅក្នុងគំរូអភិវឌ្ឍន៍សហគមន៍ចំរុះ អង្គការប៉ាដិក។ ក្រុមអ្នកឯកទេសផ្សេងៗទៀតក៏អាចបង្កើតឡើងដើម្បី ឆ្លើយតប និងតំរូវការរបស់មូលដ្ឋាន ។

*ប្រជាជននៅមូលដ្ឋាន ជួយប្រជាជនមូលដ្ឋាន*

អ្នកឯកទេស ធ្វើការនៅក្នុងភូមិដែលជាស្រុកកំណើតរបស់គេ។ អ្នកភូមិមានជំនឿជឿជាក់លើមនុស្សនៅក្នុងមូលដ្ឋាន ហើយអ្នកឯកទេសទាំងនោះស្គាល់ និងយល់ដឹងពីស្ថានភាពបុគ្គលនៅក្នុងភូមិ ដែលត្រូវការជំនួយពីគាត់។

នៅក្នុងភូមិនិមួយៗ មានអ្នកឯកទេស២នាក់ ស្ត្រីម្នាក់ ប្រុសម្នាក់ សំរាប់ជំនាញនិមួយៗ។ អ្នកទាំងនោះមិនត្រូវបំពេញលក្ខណ្ឌជាមុនទេៈ អ្វីដែលសំខាន់បំផុតនោះ គឺអ្នកឯកទេសនោះចង់ និងមានលទ្ធភាពរៀនសូត្រ ហើយមានបំណងប្រាថ្នា ផ្តល់សេវាដល់អ្នកឯទៀត នៅក្នុងភូមិរបស់គេ។

*ផ្តល់ពត៌មានសំរាប់ធ្វើផែនការអភិវឌ្ឍន៍*

អ្នកឯកទេសតាមភូមិនិមួយៗ បានមកជួបជុំគ្នាដើម្បីបង្កើតក្រុមអ្នកឯកទេសថ្នាក់ឃុំ។ គឺជាគណៈកម្មការឯកទេសក្រៅផ្លូវការ ដែលដើរតួជាអ្នកផ្តល់យោបល់ឱ្យ គ អ ភ និង គ អ យ អំពីផ្នែកបច្ចេកទេស ក្នុងការធ្វើផែនការភូមិ និងគំរោងផ្សេងៗទៀត។

គណៈកម្មការឯកទេសថ្នាក់ឃុំ សំរបសំរួលសកម្មភាពនានារបស់ភូមិ ទៅតាមបច្ចេកទេសរបស់ខ្លួន និងសហការជាមួយអង្គការប៉ាដិក និងអ្នកជំនាញ ពីខាងក្រៅផ្សេងៗទៀត ដើម្បីស្វែងរកធនធានទាំងឡាយ។ គណៈកម្មការឯកទេសថ្នាក់ឃុំ ជួបប្រជុំជាទៀងទាត់។ កិច្ចប្រជុំបែបនេះ ផ្តល់ឱកាសឱ្យក្រុមអាចធ្វើការប្រៀបធៀប នូវសភាពការនានានៅក្នុងភូមិ ពិភាក្សាកង្វល់ថ្មីៗទៀត និងដើម្បីចែករំលែកពត៌មាន ព្រមទាំងយុទ្ធសាស្ត្រនានា ឱ្យគ្នាទៅវិញទៅមក



*ក្រុមឯកទេសជាធនធានមនុស្សដែលមានចំណេះដឹងផ្នែកជំនាញនៅក្នុងសហគមន៍របស់គេ។គេរស់នៅក្នុងសហគមន៍ហើយជាអ្នកជួយប្រជាជនក្នុងភូមិតាមរយៈបច្ចេកទេសរបស់គេ។*

សំរាប់អភិវឌ្ឍន៍សហ គមន៍របស់ពួកគេ។

*ការកសាងសម្ថភាព*

អ្នកឯកទេសទទួលវគ្គហ្វឹកហ្វឺនផ្នែក បច្ចេកទេសយ៉ាងទៀងទាត់ និងវគ្គរំលឹកឡើងវិញ ដែលពាក់ពន្ធ័ទៅ និងជំនាញឯកទេសរបស់គេ ដែលផ្តល់អោយដោយបុគ្គលិកប៉ាដិក និងអ្នកបច្ចេកទេសផ្សេងៗទៀតពីខាងក្រៅ។



អង្គការប៉ាដិក ជួយពង្រីងជំនាញផ្សព្វផ្សាយឯកទេសផ្សេងៗ ដោយបង្កើតជាវគ្គ " ហ្វឹកហ្វឺនកសិករក្លាយជាគ្រូ " ។ វគ្គហ្វឹកហ្វឺននេះ បង្កើនសមត្ថភាពអ្នកឯកទេសដើម្បីឱ្យគាត់ អាចផ្សព្វផ្សាយចំណេះដឹងបន្តដល់កសិករផ្សេងៗទៀត។

*ជាសេវាកម្មមួយសំរាប់ថ្ងៃអនាគត*

គណៈកម្មការឯកទេសថ្នាក់ឃុំ គឺជាគណៈកម្មការក្រៅផ្លូវការ ដែលបានទទួលការគោរពពីសមាជិកសហគមន៍ ដោយសារ ភាពត្រឹមត្រូវ សេចក្តីមេត្តា ក្នុងការផ្តល់សេវាដែលធ្វើឱ្យពួកគេអាចទុកចិត្តបាន។ សកម្មភាព ទាំងឡាយរបស់ពួកគេ គឺដើម្បីបំពេញការខ្វះខាត សេវាកម្មនៅក្នុងភូមិ ផ្តល់លទ្ធភាពឱ្យប្រជាជន ទទួលបានចំណេះដឹង សមស្រប និងកិច្ចសង្គ្រោះដែលគេមិនអាចទទួលយកបាន ។

អ្នកឯកទេសអាចយកថ្លៃពីសេវាកម្ម របស់គាត់ ជាឧទាហរណ៍ ថ្លៃទិញថ្នាំវ៉ាក់សាំង និងថ្លៃធ្វើដំណើរ។ អង្គការប៉ាដិកសង្ឃឹមថា ប្រពន្ធ័ អ្នកឯកទេសក៏រតភូមិ និងវិវត្តន៍ទៅជាអង្គភាពស្វយ័តដែលមាន កិច្ចសន្យាជាមួយសហគមន៍ ដោយផ្អែកលើការ លើកទឹកចិត្ត ដោយយកថ្លៃសេវាថោក និងសំខាន់ជាងនេះទៅទៀត គឺគំនិតទទួលខុសត្រូវរបស់ពួកគេ ក្នុងការជួយដល់អ្នកដែលត្រូវការចាំបាច់នៅក្នុងភូមិ

តាមរយៈការផ្តល់សេវាសាធារណៈ ដ៏មានគុណតំលៃមួយ ។

## បន្ទាត់ខ្លីៗ៖ ស្តីពីអ្នកឯកទេស

-គកសឃ (គណៈកម្មការកសិកម្មសមស្រប ថ្នាក់ឃុំ) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបណ្តុះបណ្តាល ដល់កសិករអំពី ដំណាំស្រូវ បន្លែ ដំណាំហូបផ្លែ និងការដាំដំណាំរួមផ្សំតាមវិធីសាស្ត្រដែលសមស្រប ដោយប្រើទុន ពីខាងក្រៅក្នុងកំរិតទាបបំផុត ។ ការងារទាំងនេះរួមមានការថែរក្សា និងធ្វើអោយមាននិរន្តភាពគុណភាពដី ការគ្រប់គ្រងសត្វល្អិតចង្រៃដោយមិនប្រើថ្នាំគីមី និងរបៀបប្រើប្រាស់ធនធានទឹក ក្នុងលក្ខណៈសមស្របបំផុត ។

-គភពសឃ (គណៈកម្មការភ្នាក់ងារពេទ្យសត្វថ្នាក់ឃុំ) ផ្តល់ការបណ្តុះបណ្តាលដល់កសិករ អំពីការចិញ្ចឹមសត្វ រួមមានការផ្តល់ចំណីការធ្វើទ្រុង ការព្យាបាលជំងឺ ការការពារជំងឺ និងផ្តល់ពត៌មានអំពីការរកទីផ្សារសំរាប់លក់ ។ គណៈកម្មការនេះ រៀបចំការចាក់វ៉ាក់សាំងការពារជំងឺសត្វជាទៀងទាត់ តាមការស្នើសុំរបស់កសិករហើយពេលខ្លះពួកគេ សហការជាមួយការិយាល័យសុខភាពសត្វ របស់រដ្ឋាភិបាល ។

-គផចតឃ (គណៈកម្មការផ្សព្វផ្សាយការចិញ្ចឹមត្រីថ្នាក់ឃុំ) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបណ្តុះបណ្តាលដល់កសិករ អំពីការចិញ្ចឹមត្រី តាំងពីរបៀបផ្សាំកូនត្រីម្សៅរហូតដល់ត្រីយកសាច់ វិធីសាស្ត្រជីកនាំរបៀបជីកស្រះ និងការថែរក្សាស្រះ ។

-គគអឃ (គណៈកម្មការគ្រូអក្ខរកម្មថ្នាក់ឃុំ) បើកថ្នាក់អក្ខរកម្មសំរាប់មនុស្សចាស់ និងធ្វើការសំរបសំរួល ជាមួយការិយាល័យអប់រំមនុស្សចាស់ថ្នាក់ស្រុក ដើម្បីធ្វើការប្រឡង ។ ពួកគេរក្សាទុកនូវបញ្ជីទិន្នន័យ អំពីកំរិតអក្ខរភាពក្នុងភូមិនិងត្រួតពិនិត្យការប្រើប្រាស់បណ្ណាល័យចល័ត ។

- គឆប (គណៈកម្មការឆ្មបបូរាណ) ផ្តល់ពត៌មានដល់ស្ត្រីនៅក្នុងភូមិ អំពីការថែទាំសុខភាព នៅពេលមុន និង ក្រោយពេលសំរាលកូន និងពីរបៀបថែរក្សាកូនខ្ចី ។ ឆ្មបបូរាណជួយក្នុងការសំរាលកូន និងជួយផ្សព្វផ្សាយអំពីផែនការគ្រួសារ ។

-គភសឃ (គណៈកម្មការភ្នាក់ងារសុខភាពថ្នាក់ឃុំ) ចូលរួមប្រជុំក្រុមជួយខ្លួនឯង យ៉ាងទៀងទាត់ ដើម្បីផ្តល់នូវពត៌មានពីបញ្ហាទាក់ទង នឹងអាហាររូបត្ថម្ភជំងឺអេដស៍ និងជំងឺទូទៅ ។ គណៈកម្មការ បានធ្វើការជាមួយមន្ត្រីសុខភាព នៅពេលមានជំងឺរាតត្បាតកើតឡើង និងរៀបចំទិវាចាក់ថ្នាំការពារជំងឺសំរាប់ កូនក្មេង និងស្ត្រីមានផ្ទៃពោះ ។

-គបយឃ (ក្រុមបណ្តុះបណ្តាលយែនឌ័រថ្នាក់ឃុំ) ផ្តល់ការបណ្តុះបណ្តាល អំពីការយល់ដឹងនិងការបញ្ជ្រាបយែនឌ័រ ។ ពួកគេចូលរួមក្នុងដំណើរការសំរបសំរួលក្នុងឃុំ ដើម្បីធានាថា រាល់កង្វល់យែនឌ័រត្រូវបានគេ លើកយកមកពិចារណាយ៉ាងល្អិតល្អន់ និងធានាថាស្ត្រីនៅក្នុងឃុំ គឺជាអ្នកចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ ឃុំរបស់គេ ។



កសិកម្មចិញ្ចឹមត្រីលក្ខណៈគ្រួសារ



វគ្គបណ្តុះបណ្តាលភ្នាក់ងារសុខភាពភូមិ

គ្រួសារខ្វះស្បៀងអាហារ
នៅឆ្នាំ ២០០២
**(ភាគរយនៃគ្រួសារទាំងអស់)**




*ប៉ាឌិកបានធ្វើការនៅក្នុង"ឃុំចាស់" មានរយៈពេល ជាង៥ឆ្នាំហើយនៅក្នុង"ឃុំថ្មី" មានរយៈពេល តិចជាង ២ឆ្នាំ*

### នាំកសិករឱ្យធ្វើការជាមួយគ្នា

អង្គការប៉ាឌិក លើកទឹកចិត្តការធ្វើបណ្តាញការងាររវាងកសិករនិងកសិករមិនត្រឹមតែនៅក្នុងឃុំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរវាងខេត្ត និងខេត្តទៀតផងដោយសង្ឃឹមថា នឹងបំបិនទស្សនៈវិស័យ រួមមួយរបស់កសិករស្តីពីការអភិវឌ្ឍន៍ជាតិ ។ សកម្មភាពនេះត្រូវបានគេធ្វើឡើងតាមរយៈវគ្គ បណ្តុះបណ្តាលតាមបណ្តាអង្គភាពគាំទ្រតំបន់នានា ឬការធ្វើទស្សនៈកិច្ចសិក្សា ដើម្បីរៀនសូត្រ ពីបទពិសោធន៍របស់កសិករដទៃទៀត ។

លោក ទី ឡូ ជាអ្នកបណ្តុះបណ្តាលយែនឌ័រ ថ្នាក់ភូមិមកពី ឃុំពោធិចំរើន ខេត្តកំពង់ស្ពឺ គាត់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីយែនឌ័រនៅខេត្តសៀមរាបកាលពីឆ្នាំ ២០០២ ។គាត់មានប្រសាសន៍ថា " *ខ្ញុំបានជួប និងបានក្លាយជា មិត្តភក្តិជាមួយប្រជាជនមកពីទីកន្លែងផ្សេងៗ ខ្ញុំ បានហូបអាហារជុំគ្នានៅប្រាសាទអង្គរវត្ត ហើយខ្ញុំបានឃើញជាលើកទីមួយ នូវធម្មជាតិ និងសម្រស់ ដ៏ឆើតឆាយ នៃមាតុភូមិរបស់ខ្ញុំ* " ។

# ៦.ការងារនៅខេត្តសៀមរាប

## ទិសដៅ អភិវឌ្ឍន៍របស់អង្គការប៉ាឌិក

អង្គការប៉ាឌិកមាន ទិសដៅអភិវឌ្ឍន៍បួន។ ទិសដៅនិមួយៗ បង្ហាញដោយ ទ្រនិច ផលប៉ះពាល់មួយចំនួន។ ខាងក្រោមនេះជាការ បង្ហាញនូវរបាយការណ៍ អំពីទ្រនិចទាំងនោះដូចជា:

### ១.ការកសាងអង្គការ

បណ្ដាអង្គការសង្គមស៊ីវិល ដែលមានសមត្ថភាពក្នុងការគ្រប់គ្រង និងសំរបសំរួលធនធាន សំរាប់ការអភិវឌ្ឍន៍ពេញលេញនៃសហគមន៍របស់ពួកគេ។




***គអភ* ដែលអាចដំណើរការបាន**

***សេចក្ដីពន្យល់អំពី គអភ ដែលអាចដំណើរការបាន (សូមមើលទំព័រ ១១)***

### ២.សន្តិសុខស្បៀង និងការកេទ្រាក់ចំណូល

បណ្ដាអង្គការសង្គមស៊ីវិល មានសមត្ថភាពអាចធ្វើឱ្យប្រសើរឡើង នូវសន្តិសុខស្បៀង និងការរកប្រាក់ចំណូលរបស់សហគមន៍។




***កុមារ* អាយុក្រោម៥ឆ្នាំខ្វះជីជាតិ (ភាគរយ កុមារខ្វះជីជាតិ)**



*ទំនប់នៅក្នុងឃុំលាងដៃ អាចស្រោចស្រព្វដីបាន ៦៨១ហិតតា (៦៤%នៃផ្ទៃដីដាំដុះសរុប)*

## កសិកម្មសមស្រប ជា ឫសគល់នៃសន្តិសុខស្បៀង

លោកស្រី ឃោ ចាន់តារា អ្នកគ្រប់គ្រងគំរោងតំបន់សៀមរាប បាននិយាយថា ដីចំការជាច្រើននៅជុំវិញភូមិក្នុងឃុំលាងដៃ សុទ្ធតែមានរងដំណាំពិសេសដំណាំឪឡឹកដោយពួកគេអនុវត្ត ការដាំដុះតាមវិធីកសិកម្មសមស្រប។

គាត់មានប្រសាសន៍ថា: ប្រុសៗជាអ្នកភ្ជួររាស់ដីជីករណ្ដៅតូចៗ ប្រពន្ធគាត់យកជីកំប៉ុស្តទៅដាក់ក្នុងរណ្ដៅ ហើយចុងក្រោយគាត់ដាក់គ្រាប់ពូជឪឡឹកដាំតែម្ដង។ កាលពីមុនគេដាំតាមដីទំនាបពុំមានដាក់ជីកំប៉ុស្ត ធ្វើឱ្យឪឡឹកមានផ្លែតូចៗកសិករលក់នៅទីផ្សារបានដំលៃថោក។ បច្ចុប្បន្ននេះឪឡឹកផ្លែធំជាងមុន ដូច្នេះប្រជាជនមានចំណូលច្រើន។

ក្នុងឃុំលាងដៃបច្ចុប្បន្ន ប្រជាជនដាំដំណាំឈើហូបផ្លែ និងបន្លែបង្កាផ្សេងៗ តាមវិធីសរីរាង្គដោយប្រើជីធម្មជាតិ សំរាប់ហូបក្នុងគ្រួសារ។ ដំណាំពោត ល្ពៅ សណ្ដែកគួរ ផ្សិត ត្រសក់ត្រលាច ល្ហុង អំពៅ ចេក ។ល។ កសិករធ្វើការពិសោធន៍ដោយដាំដំណាំផ្សេងៗចំរុះគ្នា ផ្អែកតាមការអនុវត្តល្អៗ របស់កសិករនៅកន្លែងផ្សេងៗទៀត ហើយការខំប្រឹងប្រែងរបស់គាត់បានទទួលផលច្រើន។

នៅឆ្នាំ១៩៩៦ គ្រួសារកសិករ៨០ភាគរយ ក្នុងឃុំលាងដៃបានជួបប្រទះកង្វះស្រូវហូប យ៉ាងតិច៣ខែក្នុង១ឆ្នាំ។ កុមារ ក្រោមអាយុ៥ឆ្នាំ មាន២ភាគ៣ បានជួបប្រទះកង្វះអាហាររូបត្ថម្ភ។ នៅឆ្នាំ២០០២ អត្រាកុមារ ខ្វះអាហារូបត្ថម្ភបានថយចុះមកនៅត្រឹម២០ភាគរយ។ គ្រួសារកសិករ ១៥% នៅតែជួបប្រទះ និងការខ្វះខាតស្បៀងអាហារ។

## សន្តិសុខស្បៀងតាមរយៈការដាំដំណាំចំរុះច្រើនមុខ

ជារឿយៗកសិដ្ឋានរបស់ ភ្នាក់ងារអ្នកឯកទេសកសិកម្មសមស្របភូមិ តែងក្លាយជា សាលាបណ្ដុះបណ្ដាលនៅមូលដ្ឋាន។ គេសាកល្បងពូជ

*(តនៅទំព័រទី១៦)*

## ៣_អប់រំ និងវប្បធម៌

**បណ្តាអង្គការសង្គមស៊ីវិល មានសមត្ថភាពកសាងបណ្តាញការងារជាមួយរដ្ឋាភិបាលនិងស្ថាបន័នានា ដើម្បីអប់រំសហគមន៍របស់ខ្លួន ឱ្យយល់ពីតំលៃនៃការសិក្សាសំរាប់ជនគ្រប់រូបនិងថែបំប៉នវប្បធម៌ដែលមិនជិះជាន់គេ។**




ការចូលរួម ការអប់រំរបស់កុមារីក្នុងឆ្នាំ ២០០២
(ភាគរយនៃការចូលរួមរបស់កុមារី)
អង្គការប៉ាដិក បានធ្វើការជាមួយឃុំចាស់ចំនួនជាង ៥ឆ្នាំ និងឃុំដែលថ្មី មានរយៈពេលតិចជាង២ឆ្នាំ។

## ៤_សុខភាព

**បណ្តាអង្គការសង្គមស៊ីវិល មានសមត្ថភាពកសាងបណ្តាញការងារ ជាមួយរដ្ឋាភិបាល និងស្ថាបន័ នានា ដើម្បីជំរុញនិងអនុវត្តការយល់ដឹង ពីសុខភាព និងអនាមយ័សំរាប់គ្រប់រូប។**




ប្រជាជនបានប្រើប្រាស់ទឹកស្អាត ក្នុងឆ្នាំ ២០០២
(ភាគរយគិតជាគ្រួសារ)
អង្គការប៉ាដិកបានធ្វើការជាមួយឃុំចាស់ចំនួនជាង ៥ឆ្នាំ និងឃុំដែលថ្មី មានរយៈពេលតិចជាង២ឆ្នាំ។

### សន្តិសុខស្បៀងតាមរយៈការ,,,,

ដំណាំនិងបច្ចេកទេសថ្មីៗ ហើយកសិករផ្សេងៗទៀតក៏អាចសំរេចចិត្ត ថាតើវាជាអ្វីដែលគេគួរសាកល្បងដែរឬទេ? មើលតាមលទ្ធផលរបស់អ្នកឯកទេស ។

យើងបានជួបស្ត្រីម្នាក់ ជាអ្នកឯកទេសភូមិ ដែលគាត់សរសើរពីជីកំប៉ុស្តរបស់គាត់ មិនបាច់ចំណាយលុយអ្វីទាំងអស់ ហើយមានភាពងាយស្រួលក្នុងការផលិត និងផ្តល់ជីជាតិដល់ដីបានល្អបំផុតមែន។ គាត់បានកាយត្រលប់កំប៉ុស្តដោយកាយវិការរីករាយនិងប្រាប់យើងថារណ្តៅកំប៉ុស្តទាំងពីរនេះនិងអាចប្រើប្រាស់បានក្នុងរយៈពេល៣ខែ។

ក្នុងបរិវេណផ្ទះរបស់គាត់ ក៏មានកន្ត្រកដាក់សំរាមសំរាប់ធ្វើជីកំប៉ុស្តផងដែរ។ នេះជាវិធីមួយដែលគាត់បានទទួលពី អ្នកឯកទេសកសិកម្មសមស្របម្នាក់ទៀត ហើយគាត់ព្យាយាមអនុវត្តតាម។ គាត់បានបន្តទៀតថាវាជាវិធីផលិតជីកំប៉ុស្ត ដែលមានគុណភាពល្អ ក្នុងរយៈពេលមួយខ្លី។ តែវិធីនេះតំរូវអោយគាត់ លើកកន្ត្រកក្រឡុកជារៀងរាល់ថ្ងៃ ឱ្យចូលខ្យល់ ដើម្បីឱ្យកំប៉ុស្តកាច់បានល្អ ដែលជាការលំបាកសំរាប់គាត់ដោយសារវាធ្ងន់ពេក។

គាត់បន្តទៀតថា វិធីនេះទទួលបានផលប្រយោជន៏ច្រើនចំពោះគ្រួសារ ដែលមានកំលាំង បុរសនៅផ្ទះ(ព្រោះគាត់ជាស្ត្រីមេម៉ាយ) តែគាត់ប្តេជ្ញាបន្តផលិតជីកំប៉ុស្ត តាមវិធីនេះមួយរដូវទៀត ក្រែងមានកសិករដ៏ទៃចង់ធ្វើតាម។

*ក្នុងឆ្នាំ២០០១ នៅឃុំលាងដៃមានគ្រួសារ៩២ភាគរយ ប្រើប្រាស់ជីកំប៉ុស្ត សំរាប់ផលិតដំណាំកសិកម្មរបស់គេ បើធៀប និងឆ្នាំ១៩៩៨ ដែលមានត្រឹមតែ ២១ ភាគរយ ប៉ុណ្ណោះដែលបានបង្កើនគុណភាពដី ដោយប្រើជីធម្មជាតិ។*

### ការសំរបសំរួល ជំនួយសង្គ្រោះបន្ទាន់ដោយ ទឹកជំនន់

តំបន់ជាច្រើន នៅក្នុងខេត្តព្រៃវែង បានទទួលរងគ្រោះខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារទឹកជំនន់ក្នុងឆ្នាំ២០០១។ ក្នុងនោះរួមមាន២៥ភូមិស្ថិតក្នុងតំបន់គាំទ្ររបស់អង្គការប៉ាដិក។

